ក្រសួងពាណិជ្ជកម្ម

មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន

# ដំណើរវិវឌ្ឍន៍នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន

# THE CURRENT DEVELOPMENT OF ASEAN ECONOMIC COMMUNITY




ចងក្រងដោយ៖ នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម
នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម

លេខ ២

ចងក្រងដោយៈ **នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម**

**នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម**

គាំទ្រការបោះពុម្ពដោយៈ **មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន**

ប្រមូល និងពិនិត្យឯកសារៈ ការិយាល័យច្រកចូលទីផ្សារ

នៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

បកប្រែ និងសម្រួលខ្លឹមសារ (ក្រៅផ្លូវការ)

១. លោក **ឃិត ឧត្តមស៊ីដារ៉ា** ប្រធានការិយាល័យ
នៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

២. លោក **សុខ សុវណ្ណ** អនុប្រធានការិយាល័យ
នៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

៣. លោកស្រី **ចៅ ហី** មន្ត្រីនៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

ចងក្រង និងពិនិត្យខ្លឹមសារ

១. លោក **គិត ភារ៉ា** ប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

២. លោកស្រី **ប៊ុន ចំណាន** អនុប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

៣. មន្ត្រីការិយាល័យច្រកចូលទីផ្សារ នៃនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

# មាតិកា


**<u>ពិពណ៌នា</u>** **<u>ទំព័រ</u>**

អារម្ភកថា

១. ពាក្យហៅកាត់..........................................................................................៥

២. ព័ត៌មានទូទៅរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ........................................... ៧

២.១. សេចក្តីផ្តើម.......................................................................................... ៧

២.២. មូលដ្ឋានអាស៊ាន និងអត្តសញ្ញាណអាស៊ាន..............................................................៨

២.៣. សសរស្តម្ភសហគមន៍អាស៊ាន ......................................................................៩

២.៤. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង ................................................................ ១០

២.៥. និមិត្តសញ្ញា និងទង់អាស៊ាន ..........................................................................១២

៣. ដំណើរឆ្ពោះមកកាន់សហគមន៍សេដ្ឋកិច្ចអាស៊ាន.............................................................១៣

៤. សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ............................................................... ១៨

៥. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (The ASEAN Free Trade Area "AFTA") .................... ២៣

៥.១. ការផ្តួចផ្តើមគំនិតសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម.....................................................២៦

៥.២. ការរៀបចំពាណិជ្ជកម្មផ្អែកលើបទបញ្ញត្តិ ............................................................ ២៧

៥.៣. គោលដៅចុងក្រោយនៃ AFTA៖ ផ្តោតលើការលុបពន្ធនាំចូលទាំងអស់ .......................២៨

៥.៤. ការតភ្ជាប់សេដ្ឋកិច្ចក្រៅតំបន់........................................................................២៨

៦. វឌ្ឍនភាពនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន..................................................................៣០

៧. សហគមន៍អាស៊ាន និងដៃគូសន្ទនា....................................................................... ៤១

៨. ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន.......................................................៥៧

៨.១. ទំនាក់ទំនងការទូត..................................................................................៥៧

៨.២. ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ជប៉ុន ................................................ ៥៨

៨.៣. ការវិនិយោគជប៉ុន នៅកម្ពុជា ......................................................................... ៥៩

៨.៤. ចំនួនភ្ញៀវទេសចរណ៍ជប៉ុន មកទស្សនាកម្ពុជា .......................................................៦០

៩. ការចូលរួមរបស់កម្ពុជានៅក្នុងសហគមន៍អាស៊ាន និងទំនាក់ទំនងជាមួយដៃគូ....................... ៦១

១០. សន្និដ្ឋាន ............................................................................................... ៦៤

ឯកសារយោង ............................................................................................ ១២២

# អារម្ភកថា

ជាការពិតណាស់ ១៩ឆ្នាំកន្លងមកហើយ ដែលកម្ពុជាយើង បានចូលជាសមាជិករបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (១៩៩៩-២០១៨) ហើយប្រទេសជាសមាជិកអាស៊ានទាំង១០ បានចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានកាលពីចុងខែធ្នូ ឆ្នាំ២០១៥ កន្លងមក។ ចក្ខុវិស័យរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺបង្កើតឡើងក្នុងគោលដៅធ្វើឲ្យតំបន់អាស៊ានទាំងមូលក្លាយជាទីផ្សាររួម ជាមូលដ្ឋានផលិតកម្មរួម និងធ្វើឲ្យមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម វិនិយោគ មូលធន ពលកម្មជំនាញ និងពោរពេញដោយថាមពលសម្រាប់ប្រកួតប្រជែងជាមួយពិភពលោក។ ដោយមើលឃើញពីអត្ថប្រយោជន៍ និងឱកាសដ៏សម្បូរបែប ក្រសួងពាណិជ្ជកម្ម បានរៀបចំចងក្រងនូវឯកសារទាំងនេះឡើង ដើម្បីលើកកម្ពស់ការយល់ដឹងដល់ភាគីពាក់ព័ន្ធទាំងអស់ អំពីការវិវឌ្ឍនៃការធ្វើសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន និងជាចំណេះដឹងទូទៅក្នុងក្របខ័ណ្ឌសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលផ្តល់នូវកាលានុវត្តភាពសម្រាប់ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ដោយឈរលើសសរស្តម្ភទាំងបួន ឆ្ពោះទៅរកការតភ្ជាប់សេដ្ឋកិច្ចក្រៅតំបន់ពេញលេញ និងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់។

ក្នុងបរិបទនេះ អាស៊ាន មានការវិវឌ្ឍយ៉ាងឆាប់រហ័សលើការអភិវឌ្ឍប្រកបដោយការប្រកួតប្រជែងខ្ពស់ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច បច្ចេកទេស ពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងតំបន់ និងពិភពលោក។ សេដ្ឋកិច្ច គឺជាកត្តាដ៏សំខាន់មួយដែលត្រូវយកចិត្តទុកដាក់ ម្យ៉ាងទៀតតំបន់អាស៊ីនៅតែជាចំណុចខ្លាំងនៃកំណើនសេដ្ឋកិច្ចពិភពលោក ដូចនេះសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) មានតួនាទីដ៏សំខាន់នៅក្នុងការទ្រទ្រង់សេដ្ឋកិច្ចក្នុងតំបន់ ជាពិសេសការពង្រីកវិសាលភាពរបស់អាស៊ានជាមួយដៃគូពាណិជ្ជកម្ម និងជាទីផ្សារដ៏ធំមួយក្នុងសកលលោក។ សហគមន៍សេដ្ឋកិច្ចអាស៊ាន មានផលិតផលសរុបក្នុងស្រុករួមគិតជាទឹកប្រាក់ប្រមាណជាង ២.៦ទ្រីលានដុល្លារសហរដ្ឋអាមេរិក ឈរនៅលេខរៀងទី៦ នៃមហាអំណាចសេដ្ឋកិច្ចពិភពលោក។ ម្យ៉ាងទៀត អាស៊ានមានប្រជាជនសរុបជាង ៦៣៤.៥លាននាក់ ដែលធ្វើឲ្យអាស៊ានក្លាយជាទីផ្សារធំលំដាប់ទី៣ និងមានប្រជាជនច្រើនជាងគេ បន្ទាប់ពីចិន និងឥណ្ឌា។ ផែនការមេរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥ ដែលបានអនុម័តក្នុងកំឡុងពេលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី បានផ្តោតលើយុទ្ធសាស្ត្រសំខាន់ៗ ក្នុងការដឹកនាំអាស៊ានឆ្ពោះទៅសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ២០១៦-២០២៥។

## ១. ពាក្យហៅកាត់

| | |
|---|---|
| AAECP | : ASEAN-Australia Economic Cooperation Programme |
| ACF | : ASEAN Cultural Fund |
| ACIA | : ASEAN Comprehensive Investment Agreement |
| ADMM – Plus | : ASEAN Defence Ministers' Meeting Plus |
| AEC | : ASEAN Economic Community |
| AEM | : ASEAN Economic Ministers Meeting |
| AEM–METI | : ASEAN Economic Ministers – Minister for Economy, Trade and Industry |
| AFAS | : ASEAN Framework Agreement on Services |
| AFTA | : ASEAN Free Trade Area |
| AHTN | : ASEAN Harmonized Tariff Nomenclature |
| AIA | : Framework Agreement on ASEAN Investment Area |
| AJCCST | : ASEAN-Japan Cooperation Committee on Science and Technology |
| AJCEP | : ASEAN-Japan Comprehensive Economic Partnership |
| AJCTD | : ASEAN-Japan Counter Terrorism Dialogue |
| AJEEP | : ASEAN-Japan Energy Efficiency Partnership Programme |
| AJIN | : ASEAN Japan Innovation Network |
| AJTP | : ASEAN-Japan Transport Partnership |
| AMAF | : ASEAN Ministers on Agriculture and Forestry |
| AMMTC+Japan | : ASEAN + Japan Ministerial Meeting on Transnational Crimes |
| AMS | : ASEAN Member States |
| APT | : ASEAN Plus Three |
| ARF | : ASEAN Regional Forum |
| ASA | : Association of Southeast Asia |
| ASEAN | : Association of Southeast Asia Nation |
| ASEAN-6 | : the six major and older nations in ASEAN, including Brunei, Indonesia, Malaysia, Philippines, Singapore and Thailand |
| ASEAN IGA | : ASEAN Investment Guarantee Agreement |
| ASP | : ASEAN Sub-Regional Program |
| ASTFI | : ASEAN Seamless Trade Facilitation Indicators |
| ATF-SAP | : AEC 2025 Trade Facilitation Strategic Action Plan |
| ATIGA | : ASEAN Trade in Goods Agreement |
| ATISA | : ASEAN Trade in Services Agreement |
| AWPEC | : ASEAN Work Programme on Electronic Commerce |

| | |
|---|---|
| CEPT | : Agreement on the Common Effective Preferential Tariff |
| CER | : Closer Economic Relation |
| CLMV | : Cambodia, Lao, Myanmar, Vietnam |
| EAS | : East Asia Summit |
| EIP | : Environmental Improvement Program |
| EMTIPS | : Energy Efficiency Market Transformation with Information Provision Scheme |
| FAST Agenda | : Focused and Strategic Agenda |
| FTA | : Free Trade Area |
| FJCCIA | : Federation of Japanese Chamber of Commerce and Industry in ASEAN |
| GDP | : Gross Domestic Product |
| IAI | : Initiative for ASEAN Integration |
| IATEP | : Inter-ASEAN Technical Exchange Programme |
| IB | : Inclusive Business |
| IEC | : International Electrotechnical Commission |
| IILP | : Inter-Institutional Linkages Programme |
| ISO | : International Standards Organization |
| ITU | : International Telecommunication Union |
| JAEP | : Japan-ASEAN Exchange Programme |
| JAIF | : Japan ASEAN Integration Fund |
| JCC | : Joint Cooperation Committee |
| MSMEs | : Micro Small Medium Enterprises |
| NTBs | : Non-Tariff Barriers |
| RCEP | : Regional Comprehensive Economic Partnership |
| R&D | : Research and Develop |
| SMEs | : Small and Medium Enterprises |
| SOME | : Senior Officials Meeting on Energy |
| SOM-TC | : Senior Officials Meeting on Transnational Crime |
| PITO | : ASEAN Private Investment and Trade Opportunities |
| SCF | : Special Cooperation Fund |
| TAC | : Treaty of Amity and Cooperation |
| TIPP | : Trade and Investment Promotion Programme |
| TEL | : Temporary Exclusive List |
| UNDP | : United Nations Development Program |
| WTO | : World Trade Organization |
| ZOPFAN | : Zone of Peace, Freedom and Neutrality |

## ២. ព័ត៌មានទូទៅរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)

### ២.១. សេចក្តីផ្តើម

**អាស៊ាន** ត្រូវបានបង្កើតឡើងដំបូងបង្អស់ក្នុងឆ្នាំ១៩៦១ ដែលមានទម្រង់ជាអង្គភាព និងមានឈ្មោះថា "**សមាគមអាស៊ីអាគ្នេយ៍**" (Association of Southeast Asia "ASA") និងមានប្រទេសចូលរួមចំនួន ០៣ប៉ុណ្ណោះ គឺសាធារណរដ្ឋហ្វីលីពីន សហព័ន្ធម៉ាឡេស៊ី និងព្រះរាជាណាចក្រថៃឡង់ដ៍។ រហូតដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ រដ្ឋមន្ត្រីការបរទេស នៃបណ្តាប្រទេសចំនួន ០៥ ជាសមាជិកហត្ថលេខី គឺព្រះរាជាណាចក្រថៃឡង់ដ៍ សហព័ន្ធម៉ាឡេស៊ី សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋហ្វីលីពីន និងសាធារណរដ្ឋសិង្ហបុរី បានចុះហត្ថលេខាលើសន្ធិសញ្ញាអាស៊ាន ដែលត្រូវបានគេស្គាល់ថាជា "**សន្ធិសញ្ញាក្រុងបាងកក**" ក្នុងការបង្កើត និងប្តូរឈ្មោះពី "**សមាគមអាស៊ីអាគ្នេយ៍ (ASA)**" ទៅជា "**សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍**" (Association of Southeast Asia Nation "ASEAN") នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានគោលបំណងដំបូងគឺ "**ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងការប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត**"។



នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៨៤ ត្រឹមរយៈពេលមួយសប្តាហ៍ បន្ទាប់ពីព្រះរាជាណាចក្រប្រ៊ុយណេដារូសាឡឹម ទទួលបានឯករាជ្យពីចក្រភពអង់គ្លេស ប្រទេសនេះក៏បានក្លាយជាសមាជិកទី៦ និងបានធ្វើឲ្យអាស៊ានកាន់តែរីកចម្រើនថែមទៀត។ និងបានបញ្ចូលរដ្ឋជាសមាជិកទី៧ គឺសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥ និងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧ បានបញ្ចូលសមាជិកទី៨ និងទី៩បន្ថែមទៀត គឺសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ រហូតមកដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ រដ្ឋជាសមាជិកទាំង៩ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ បានឯកភាពជាឯកច្ឆន្ទ អនុញ្ញាតឲ្យព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកចុងក្រោយ ទី១០។

## ២.២. មូលដ្ឋានអាស៊ាន និងអត្តសញ្ញាណអាស៊ាន

**ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ - One Vision, One Identity, One Community** គឺជាបាវចនារបស់អាស៊ាន។ អាស៊ាន មិនខុសពីជាតិមួយ ដែលមានទង់ជាតិ និងភ្លេងជាតិផ្ទាល់ខ្លួនពោលគឺអាស៊ានក៏មានទង់អាស៊ាន និងភ្លេងអាស៊ានផងដែរ។ "**ភ្លេងអាស៊ាន**" បង្ហាញពីសាមគ្គីភាពរវាងប្រទេសសមាជិក និងការលើកកម្ពស់អត្តសញ្ញាណរបស់ខ្លួន ប៉ុន្តែភ្លេងនេះប្រគុំតែក្នុងកិច្ចប្រជុំធំៗ និងទិវាអាស៊ានតែប៉ុណ្ណោះ។

"**មូលដ្ឋានអាស៊ាន**" អគ្គលេខាធិការដ្ឋានអាស៊ាន មានមូលដ្ឋាននៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី ដែលមានអគ្គលេខាធិការទទួលបន្ទុកសម្របសម្រួល និងអនុវត្តសកម្មភាពនានារបស់អាស៊ាន ហើយអគ្គលេខាធិការនោះត្រូវតែងតាំងដោយកិច្ចប្រជុំកំពូលអាស៊ានមានអាណត្តិ ៥ឆ្នាំ និងប្តូរវេនទៅតាមលំដាប់អក្សរជាភាសាអង់គ្លេសរបស់រដ្ឋជាសមាជិក។ ម្យ៉ាងទៀតការជ្រើសរើសអគ្គលេខាធិការត្រូវផ្អែកលើធម្មនុញ្ញអាស៊ានដែលកំណត់លក្ខខណ្ឌដូចជា សុចរិត បទពិសោធន៍ការងារ សមត្ថភាព និងសមភាពយេនឌ័រ។

នៅរាល់ការសម្រេចចិត្តសំខាន់ៗដែលពាក់ព័ន្ធនឹងជោគវាសនារបស់អាស៊ាន គឺត្រូវធ្វើដោយកិច្ចប្រជុំកំពូលអាស៊ាន ដែលប្រព្រឹត្តទៅរាល់ឆ្នាំនៅប្រទេសដែលមានតួនាទីជាប្រធានអាស៊ាន។ ក្រៅពីកិច្ចប្រជុំកំពូលនៅមានកិច្ចប្រជុំដ៏ទៃទៀត ដូចជាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកជាដើម។ ប្រធានអាស៊ានត្រូវផ្លាស់ប្តូរវេនជារៀងរាល់ឆ្នាំ តាមលំដាប់អក្សរនៃឈ្មោះជាភាសាអង់គ្លេសរបស់រដ្ឋជាសមាជិកដូចមានចែងក្នុងមាត្រា៣១ នៃធម្មនុញ្ញអាស៊ាន ហើយរដ្ឋសមាជិកដែលជាប្រធានអាស៊ាននោះ ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀត។ ជាក់ស្តែង ព្រះរាជាណាចក្រកម្ពុជាធ្លាប់ធ្វើជាប្រធានអាស៊ានចំនួន២ដង គឺលើកទី១ នៅឆ្នាំ២០០២ និងលើកទី២ នៅឆ្នាំ២០១២។

## ២.៣. សសរស្តម្ភសហគមន៍អាស៊ាន

សហគមន៍អាស៊ាន មានសសរស្តម្ភ ៣ គឺៈ

**សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍**

| **សហគមន៍ នយោបាយ-សន្តិសុខ** | **សហគមន៍សេដ្ឋកិច្ច** | **សហគមន៍ សង្គម-វប្បធម៌** |
|---|---|---|
| - មូលដ្ឋានច្បាប់<br>- ចែករំលែកបទដ្ឋាន និងគុណតម្លៃ<br>- ផ្សារភ្ជាប់គ្នា សន្តិភាព ស្ថិរភាព និងការទទួលខុសត្រូវរួម<br>- ភាពរឹងមាំ និងការសម្លឹងវែងឆ្ងាយ | - ផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ<br>- សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់<br>- អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌<br>- សមាហរណកម្មតំបន់ពេញលេញទៅក្នុងសេដ្ឋកិច្ចសកល | - ការអភិវឌ្ឍធនធានមនុស្ស<br>- សុខុមាលភាពសង្គម និងការថែទាំ<br>- យុត្តិធម៌ និងសិទ្ធិសេរីភាពសង្គម<br>- និរន្តរភាពបរិស្ថាន<br>- អត្តសញ្ញាណអាស៊ាន |

## ២.៤. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

**ចក្ខុវិស័យ** គឺអាស៊ានរួបរួមជាប្រជាជាតិអាស៊ីអាគ្នេយ៍តែមួយ សម្លឹងឆ្ពោះទៅមុខ រស់នៅក្នុងសន្តិភាព ស្ថិរភាព និងវិបុលភាព សហការគ្នាជាដៃគូអភិវឌ្ឍន៍ដ៏រឹងមាំ និងជាសហគមន៍តែមួយគត់នៃសង្គមចេះយកអាសារគ្នា។

<u>គោលបំណង និងគោលដៅ</u>

គោលបំណង ដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងកិច្ចប្រឹងប្រែងក្នុងស្មារតីសមភាព ភាពជាដៃគូ និងដើម្បីរួមចំណែកឆ្ពោះទៅរកសន្តិភាព វឌ្ឍនភាព និងវិបុលភាពក្នុងតំបន់។

ដូចបានកំណត់ក្នុងសេចក្តីប្រកាសអាស៊ាន គោលបំណង និងគោលដៅនៃអាស៊ានគឺ៖

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពសង្គម រក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់
- ពង្រឹង និងពង្រីកសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍រួម នៃបណ្តាប្រទេសក្នុងតំបន់
- បម្រើការជាវេទិកាមួយសម្រាប់ដោះស្រាយការខ្វែងយោបល់គ្នានៅក្នុងតំបន់

ជារៀងដរាបមក អាស៊ានបានរក្សានូវគោលការណ៍គ្រឹះរបស់ខ្លួនរួមមាន៖

- គោរពគ្នាទៅវិញទៅមកនូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងអត្តសញ្ញាណរបស់ប្រជាជាតិសមាជិកនីមួយៗ
- មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសសមាជិក
- ដោះស្រាយទំនាស់ ឬវិវាទ ដោយសន្តិវិធី
- លះបង់ចោលនូវការរំលោភបំពាន និងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងទ័ព
- គោរពដោយខ្ជាប់ខ្ជួននូវគោលការណ៍ច្បាប់អន្តរជាតិ ដែលទាក់ទងនឹងទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក
- គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូប




- គោរពវប្បធម៌ផ្សេងៗគ្នា ភាសា និងសាសនារបស់ប្រជាជនអាស៊ាន ដោយសង្កត់ធ្ងន់ទៅលើតម្លៃរួម ក្នុងស្មារតីភាពឯកភាពក្នុងពហុភាព
- ភាពជាស្នូលរបស់អាស៊ាន ក្នុងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្រៅតំបន់ ដោយរក្សាការចូលរួមដ៏សកម្ម ការសម្លឹងមើលឆ្ពោះទៅខាងក្រៅ ភាពរួមបញ្ចូល និងមានភាពមិនរើសអើង និង
- ប្រកាន់ខ្ជាប់នូវវិធានពាណិជ្ជកម្មពហុភាគី និងរបបផ្អែកលើមូលដ្ឋានច្បាប់របស់អាស៊ាន ដើម្បីអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវកិច្ចខិតខំប្រឹងប្រែងផ្នែកសេដ្ឋកិច្ច និងកាត់បន្ថយជាវិជ្ជមានឆ្ពោះទៅលុបបំបាត់របាំងទាំងស្រុង សម្រាប់សមាហរណកម្មសេដ្ឋកិច្ចតំបន់ សេដ្ឋកិច្ចទីផ្សារ។[1]

[1] ឯកសារជំនួយស្មារតីរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ២.៥. និមិត្តសញ្ញា និងទង់អាស៊ាន




និមិត្តសញ្ញាអាស៊ាន គឺត្រូវបានរក្សាសិទ្ធិស្របច្បាប់ដោយអាស៊ាន
The ASEAN Emblem is the reserved copyright of ASEAN

**និមិត្តសញ្ញាអាស៊ាន** តំណាងឲ្យស្ថិរភាព សន្តិភាព ការរួបរួម និងថាមពល។ ក្នុងនិមិត្តសញ្ញានេះមានពណ៌ចំនួន ០៤ គឺពណ៌ខៀវ ក្រហម ស និងលឿង ដែលតំណាងឲ្យពណ៌សំខាន់ៗ នៃគ្រប់ទង់ជាតិរបស់រដ្ឋជាសមាជិកទាំងអស់ និងតំណាងអត្ថន័យតាមពណ៌នីមួយៗ ដូចជា **ពណ៌ខៀវ** តំណាងឲ្យសន្តិភាព និងស្ថិរភាព។

**ពណ៌ក្រហម** បង្កប់អត្ថន័យនៃភាពក្លាហាន និងថាមពល។ **ពណ៌ស** តំណាងឲ្យភាពបរិសុទ្ធស្អាតស្អំ និង**ពណ៌លឿង** តំណាងឲ្យនិមិត្តរូបនៃវិបុលភាព។ **រូបក្បូរស្រូវ (បាច់១០ដើម)** តំណាងឲ្យសុបិន្តរបស់បិតាស្ថាបនិកអាស៊ាន ដែលចង់បានអាស៊ានមួយមានគ្រប់ប្រទេសទាំងអស់ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួបរួមគ្នា ក្នុងមិត្តភាព និងសាមគ្គីភាព។ ចំណែក **រង្វង់** តំណាងឲ្យការឯកភាពរបស់អាស៊ាន។



ទង់អាស៊ាន គឺត្រូវបានរក្សាសិទ្ធិស្របច្បាប់ដោយអាស៊ាន
The ASEAN Flag is the reserved copyright of ASEAN

**ទង់អាស៊ាន** តំណាងឲ្យសហគមន៍អាស៊ានមួយពោរពេញដោយស្ថិរភាព សន្តិភាព ការរួបរួម និងថាមពល។ ពណ៌របស់ទង់អាស៊ានមាន៖ ពណ៌លឿង ក្រហម ខៀវ និងស ដែលតំណាងឲ្យពណ៌សំខាន់ៗ នៃគ្រប់ទង់ជាតិ របស់ប្រទេសជាសមាជិកអាស៊ានទាំងអស់។

**ទង់អាស៊ាន** គឺជានិមិត្តរូបនៃការរួបរួមរដ្ឋជាសមាជិកក្នុងការគាំទ្រនូវគោលការណ៍ និងការខិតខំប្រឹងប្រែងរបស់អាស៊ាន និងដើម្បីជំរុញការយល់ដឹងអំពីអាស៊ាន និងរួបរួមគ្នាកាន់តែខ្លាំងឡើង ។[2]

---

[2] ធម្មនុញ្ញអាស៊ាន



## ៣. ដំណើរឆ្ពោះមកកាន់សហគមន៍សេដ្ឋកិច្ចអាស៊ាន

ជាង៥០ឆ្នាំ នៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ សមាគមមួយនេះ បានវិវឌ្ឍខ្លួនក្លាយជាតំបន់ដ៏រឹងមាំមួយនៅក្នុងពិភពលោក ជាមួយនឹងការពន្លឿនសេដ្ឋកិច្ច ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទាំងនោះបានមកពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន និងការផ្តួចផ្តើមសមាហរណកម្មជាជំហានៗ ដោយភាពបត់បែនជាង ២ទសវត្សរ៍កន្លងមក។ ប្លុកតំបន់មួយនេះ បានឆ្លងកាត់បញ្ហាប្រឈមទាំងសេដ្ឋកិច្ច និងសន្តិសុខ ប៉ុន្តែបច្ចុប្បន្នអាស៊ាន បានក្លាយជាអង្គការតំបន់ ដែលជោគជ័យជាងគេមួយ និងកំពុងដើរតួនាទីស្នូលក្នុងការដាក់ចេញនូវរបៀបវារៈ ដើម្បីសន្តិភាព និងវិបុលភាពនៅក្នុងតំបន់ក៏ដូចជាសកលលោក។ បើទោះបីជា មានភាពខុសគ្នារវាងប្រទេសជាសមាជិកលើកត្តាសាវតា វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍក៏ដោយ ក៏អាស៊ានបានបង្ហាញឲ្យឃើញនូវការធ្វើសមាហរណកម្មតំបន់របស់ខ្លួនបានសម្រេចផងដែរ។ ក្នុងទសវត្សរ៍ឆ្នាំ៩០ បណ្តាប្រទេសអាស៊ានបានបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ក្នុងគោលបំណងលើកកម្ពស់ការប្រកួតប្រជែង ដោយការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ

និងឧបសគ្គមិនមែនពន្ធនៅក្នុងអាស៊ាន ហើយក៏ជាការទាក់ទាញដល់ការវិនិយោគទុនបរទេសបន្ថែមទៀតផងដែរ។

ក្នុងទស្សនៈជាប្រវត្តិសាស្ត្រ ផ្នត់គំនិតដំបូងបង្អស់ក្នុងការរួមបញ្ចូលនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន គឺត្រូវបានបង្ហាញក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀង ស្តីពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ដែលបានចុះហត្ថលេខាកាលពីឆ្នាំ១៩៩២ នៅសាធារណរដ្ឋសឹង្ហបុរី។




កិច្ចព្រមព្រៀងក៏បានរំលេចនូវកិច្ចសហប្រតិបត្តិការក្នុងតំបន់ពាណិជ្ជកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល ហិរញ្ញវត្ថុ និងវិស័យធនាគារ ម្ហូបអាហារ កសិកម្ម និងព្រៃឈើ ឲ្យកាន់តែល្អដូចជាការដឹកជញ្ជូន និងទូរគមនាគមន៍។ កិច្ចព្រមព្រៀងក្របខណ្ឌចុងក្រោយ នាំឲ្យមានការបង្កើតកិច្ចព្រមព្រៀងគន្លឹះៗដទៃយ៉ាងឆាប់រហ័ស។ កិច្ចព្រមព្រៀងស្តីពី គម្រោងអនុគ្រោះពន្ធទូទៅ សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

ត្រូវបានចុះហត្ថលេខាកាលពីឆ្នាំ១៩៩២ ដែលត្រូវជំនួសដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានលើទំនិញ ដែលត្រូវបានចុះហត្ថលេខា ឆ្នាំ២០១០វិញ ខណៈពេលដែលកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម បានចុះហត្ថលេខាតាំងពីឆ្នាំ១៩៩៥។ អាស៊ានក៏បានយកចិត្តទុកដាក់លើកិច្ចព្រមព្រៀងវិនិយោគមួយចំនួនទៀត រួមមានៈ កិច្ចព្រមព្រៀង ស្តីពីការធានាការវិនិយោគអាស៊ាន (ASEAN IGA) កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីតំបន់វិនិយោគអាស៊ាន (AIA Framework Agreement) ដែលបច្ចុប្បន្នត្រូវបានជំនួសដោយកិច្ចព្រមព្រៀង ស្តីពីការវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន ដែលត្រូវបានចូលជាធរមានកាលពីឆ្នាំ២០១២។

រហូតមកដល់កិច្ចប្រជុំកំពូលលើកទី៩ ឆ្នាំ២០០៣ ដែលបានប្រារព្ធនៅសាធារណរដ្ឋឥណ្ឌូណេស៊ី មេដឹកនាំអាស៊ានទាំងអស់បានចេញសេចក្តីប្រកាសលើកដំបូង អំពីការបង្កើតឲ្យមានAEC តាមគោលដៅព្រមព្រៀងនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ដែលត្រូវបានគេស្គាល់ថាជាសេចក្តីប្រកាស Bali Concord II។ ហើយសេចក្តីប្រកាសនេះ ក៏ស្ថិតនៅក្នុងទស្សនវិស័យអាស៊ានឆ្នាំ២០២០ (បានអនុម័តកាលពីឆ្នាំ១៩៩៧) ដែលបានកំណត់គោលដៅច្បាស់លាស់ក្នុងការបន្លាស់ប្រែអាស៊ានប្រកបដោយស្ថិរភាព វិបុលភាព និងជាតំបន់ដែលមានការប្រកួតប្រជែងខ្ពស់ ជាមួយការអភិវឌ្ឍវិស័យសេដ្ឋកិច្ចប្រកបដោយសមភាព កាត់បន្ថយភាពក្រីក្រ និងគម្លាតគ្មានទូវសង្គមសេដ្ឋកិច្ច បន្តរួមគ្នាបង្កើតសហគមន៍សន្តិសុខនយោបាយអាស៊ាន (ASEAN Political Security Community) និងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASEAN Socio-Cultural Community)។

ផែនការមេអាស៊ាន ឆ្នាំ២០១៥ ត្រូវបានផ្តួចផ្តើមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) លើកទី៣៨ នៅទីក្រុងកូឡាឡាំពួរ។ AEM ត្រូវបានព្រមព្រៀងដើម្បីបន្តអភិវឌ្ឍន៍ផែនការរួម និងការទំនាក់ទំនងជាជំហានៗ ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ យោងតាមខ្លឹមសារ ផែនការនេះត្រូវបានដាក់ឲ្យអនុវត្តតាមរយៈការកំណត់នូវលក្ខខណ្ឌ និងកត្តាមួយចំនួនស្របតាមAEC ជាមួយនឹងសេចក្តីប្រកាស

Bali Concord II ទាក់ទងនឹងគោលដៅ និងពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្ត និងការពិចារណា លើកម្រិតគម្លាតនៃការអភិវឌ្ឍរបស់រដ្ឋជាសមាជិកអាស៊ាន។

នៅខែមករា ឆ្នាំ២០០៧ ក្នុងកិច្ចប្រជុំកំពូលលើកទី១២ មេដឹកនាំអាស៊ានទាំងអស់បានព្រមព្រៀងគ្នាជារួម ដើម្បីពន្លឿនការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយប្តូរពីឆ្នាំ២០២០ មកត្រឹមឆ្នាំ២០១៥វិញ ដូចដែលមានចែងជាផ្លូវការ ក្នុងសេចក្តីប្រកាស Cebu (Cebu Declaration) ស្តីពីការពន្លឿនការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥។

***"ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន បានដើរតួជាផែនការមេគ្រប់ជ្រុងជ្រោយ ក្នុងការត្រួសត្រាយផ្លូវឆ្ពោះទៅរកការបង្កើតជាផ្លូវការនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន"***

ចក្ខុវិស័យរួមគ្នាសម្រាប់ការរួមបញ្ចូលគ្នានាពេលអនាគត ត្រូវបានអនុម័តដោយបណ្តាមេដឹកនាំអាស៊ាន កាលពីខែធ្នូ ឆ្នាំ២០០៧ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ និងបានឈានដល់ផែនការរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន។ នេះគឺជាផែនការមួយ ដែលបានដើរតួជាផែនការមេគ្រប់ជ្រុងជ្រោយក្នុងការត្រួសត្រាយផ្លូវឆ្ពោះទៅរកការបង្កើតជាផ្លូវការនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint)។

# សង្ខេបព្រឹត្តិការណ៍ AEC



## ៤. សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន

ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នៅចុងឆ្នាំ២០១៥ គឺជាសមិទ្ធផលដ៏ធំបំផុតមួយដែលអាស៊ានសម្រេចបានក្នុងគោលបំណង ដើម្បីសម្រេចបាននូវទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ចំណុចទីពីរ គឺជាតំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់ ចំណុចទីបី គឺជាតំបន់មួយដែលមានការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និងទីបួន គឺជាតំបន់មួយដែលរួមបញ្ចូលគ្នាយ៉ាងពេញលេញនៅក្នុងសេដ្ឋកិច្ចពិភពលោក។ ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ បាននឹងកំពុងផ្តល់ទិសដៅ និងវិធានការយុទ្ធសាស្ត្រទូលំទូលាយ ដើម្បីឈានទៅសម្រេចបាននូវសហគមន៍មួយ ដែលមានកម្រិតសមាហរណកម្មខ្ពស់ ស្របគ្នានឹងផែនការសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ និងផែនការសហគមន៍សង្គម-វប្បធម៌អាស៊ានឆ្នាំ២០២៥។

ដូចនេះ ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺឈរលើសសរស្តម្ភចំនួន០៤ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ដូចជា៖ ក)-ទីផ្សារ និងផលិតកម្មមូលដ្ឋានតែមួយ ខ)-តំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់ គ)-តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌ និង ឃ)-សមាហរណកម្មតំបន់ពេញលេញទៅក្នុងសេដ្ឋកិច្ចសកល។ សហគមន៍សេដ្ឋកិច្ចអាស៊ានមានលក្ខណៈគ្រប់ជ្រុងជ្រោយប្រកបដោយភាពទូលំទូលាយ និងមានវិស័យជាច្រើន ដូចមានរៀបរាប់ខាងក្រោមនេះ៖

# សហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥

### ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ

- លំហូរទំនិញដោយសេរី
- លំហូរសេវាកម្មដោយសេរី
- លំហូរការវិនិយោគដោយសេរី
- លំហូរមូលធនដោយសេរី
- លំហូរពលកម្មជំនាញដោយសេរី
- វិស័យសមាហរណកម្មអាទិភាព
- អាហារ កសិកម្ម និងព្រៃឈើ

### តំបន់សេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្ពស់

- គោលនយោបាយប្រកួតប្រជែង
- ការការពារអ្នកប្រើប្រាស់
- ច្បាប់កម្មសិទ្ធិបញ្ញា
- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
- ពន្ធដារ
- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (E-Commerce)

### តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌

- អភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម
- ផ្តួចផ្តើមសម្រាប់ការធ្វើសមាហរណកម្មអាស៊ាន

### សមាហរណកម្មតំបន់ពេញលេញទៅក្នុងសេដ្ឋកិច្ចសកល

- ផ្សារភ្ជាប់វិធីសាស្ត្រឆ្ពោះទៅរកទំនាក់ទំនងសេដ្ឋកិច្ចក្រៅតំបន់
- លើកកម្ពស់ការចូលរួមក្នុងបណ្តាញផ្គត់ផ្គង់សកល

**សសរស្តម្ភទី១៖** សំដៅស្វែងរក និងបង្កើតទីផ្សារ និងផលិតកម្មតែមួយ តាមរយៈលំហូរដោយសេរីលើទំនិញ សេវាកម្ម វិនិយោគ កម្លាំងពលកម្មជំនាញ និងមូលធន។ គោលបំណងទាំងនោះ សម្រាប់ការធ្វើសេរីភាវូបនីយកម្មទីផ្សារបន្ថែមទៀតដែលផ្តល់នូវកាលានុវត្តភាពពាណិជ្ជកម្មកាន់តែធំទូលាយដល់

ប្រជាជន និងធុរកិច្ចរួមគ្នាក្នុងតំបន់ ដោយកាត់បន្ថយថ្លៃដើមពាណិជ្ជកម្ម និងពង្រឹងប្រព័ន្ធវិនិយោគក្នុងអាស៊ាន ដើម្បីជាគោលដៅវិនិយោគកាន់តែទាក់ទាញ សម្រាប់វិនិយោគិនជាតិ និងអន្តរជាតិ។

តាមរយៈសសរស្តម្ភមួយនេះ វាបានបង្កើតឲ្យមានឱកាសទីផ្សារ ដែលអនុញ្ញាតដល់វិនិយោគិន និងធុរជនអាចបង្កើត និងបង្កើនទីផ្សាររបស់ពួកគេឈានដល់ ៦៣៤.៥លាននាក់ និងផ្អែកលើផលិតកម្មតែមួយនេះ ក៏បានអនុញ្ញាតដល់ធុរកិច្ចឲ្យមានលទ្ធភាពបំពេញតម្រូវការលើផលិតផល និងសេវាកម្មក្នុងតំបន់ ដោយបង្កើតបាននូវបណ្តាញឧស្សាហកម្មទូទាំងអាស៊ាន និងចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សកលផងដែរ។ បន្ថែមពីនេះ ក្រុមហ៊ុនដែលមានទីតាំងក្នុងអាស៊ាន អាចនាំចូលវត្ថុធាតុដើម សម្ភារនានាដែលបម្រើដល់ផលិតកម្ម សេវាកម្ម កម្លាំងពលកម្ម និងដើមទុន ពីបណ្តាប្រទេសក្នុងអាស៊ានដើម្បីយកមកដំណើរការអាជីវកម្មរបស់ពួកគេ ហើយក្រុមហ៊ុនទាំងនោះ អាចសន្សំបាននូវថ្លៃដើមផលិតកម្ម ផ្អែកលើឯកទេសកម្ម និង/ឬ រួមចំណែកបង្កើននូវទំហំសេដ្ឋកិច្ចដោយមិនចាំបាច់មានទីផ្សារសក្តានុពលខ្ពស់ក្នុងតំបន់។

ដូចគ្នានេះផងដែរ គឺវិនិយោគិន និងធុរជនអាចទទួលបាន គឺ៖

- ក្នុងខ្សែសង្វាក់ភោជនីយដ្ឋានលំដាប់ខ្ពស់ នៅក្នុងទីផ្សារផ.ស.ស.ខ្ពស់ អាចជ្រើសរើសប្រភពនៃគ្រឿងផ្សំក្នុងស្រុក ឬពីបណ្តាប្រទេសជិតខាង ក្នុងតម្លៃប្រកួតប្រជែង
- ម៉ាកសម្លៀកបំពាក់អាចបង្កើតរោងចក្ររបស់ពួកគេក្នុងប្រទេសអាស៊ាន ជាមួយតម្លៃពលកម្មទាប ប៉ុន្តែក៏ផ្តោតលើការចែកចាយក្នុងទីផ្សារអាស៊ានដ៏ធំ ដើម្បីបង្កើនប្រាក់ចំណេញ
- ក្រុមហ៊ុនផលិត ក្នុងប្រទេសអាស៊ានដែលមានចំណូលមធ្យម អាចស្វែងរកសមាសធាតុបច្ចេកវិទ្យាផលិតខ្ពស់ ពីការជំរុញលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងសេដ្ឋកិច្ចអាស៊ាន ខណៈពេលដែលទទួលបានផលប្រយោជន៍ពីក្រុមការងារជំនាញប្រកួតប្រជែងក្នុងតំបន់។
- អ្នកផ្តល់សេវាកម្មតាមវិស័យ ដូចជាទូរគមនាគមន៍ ការថែទាំសុខភាព ឬហិរញ្ញវត្ថុ អាចបង្កើតក្រុមហ៊ុនឆ្លងកាត់ពីប្រទេសមួយ ទៅប្រទេសមួយក្នុងតំបន់

- អ្នកជំនាញមកពីស្ថាប័នវិស្វកម្ម ស្ថាបត្យកម្ម និងគណនេយ្យអាស៊ាន អាចផ្លាស់ប្តូរទីតាំងទូទាំងតំបន់ និងបន្តការប្រកបរបរលើជំនាញ
- ក្រុមហ៊ុនកំពុងវិនិយោគក្នុងតំបន់ អាចត្រូវបានផ្តល់នូវប្រព្រឹត្តិកម្មមិនរើសអើង រួមបញ្ចូលទាំងប្រព្រឹត្តកម្មជាតិ និងប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត (GSP) និងទាំងនៅមុនពេលបង្កើត និងក្រោយបង្កើត ជាមួយនឹងការលើកលែងជាអប្បបរមា។

<u>**សសរស្តម្ភទី២**</u>៖ ជួយបង្កើតបរិយាកាសអាជីវកម្មកាន់តែជិតស្និទ្ធ និងគាំទ្រនវានុវត្តន៍ភាពតំបន់។ ទាំងនោះ គឺសម្រេចបានតាមរយៈការអនុម័តលើក្របខ័ណ្ឌរួម ស្តង់ដារនានា និងកិច្ចសហប្រតិបត្តិការទៅវិញទៅមកទូទាំងតំបន់ ដូចជាវិស័យកសិកម្ម សេវាកម្មហិរញ្ញវត្ថុ និងគោលនយោបាយប្រកួតប្រជែង ច្បាប់កម្មសិទ្ធិបញ្ញា និងការពារអ្នកប្រើប្រាស់។ សសរស្តម្ភនេះ ថែមទាំងគាំទ្រដល់ការពង្រឹងនូវការតភ្ជាប់បណ្តាញដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ព្រមទាំងផ្តល់នូវកាលានុវត្តភាពកាន់តែប្រសើរឡើងចំពោះប្រជាជនអាស៊ាន និងធុរកិច្ចនានា ក្នុងការបង្កើនផលិតភាពការងាររួមគ្នា និងបានជួយសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងរួមចំណែកកាត់បន្ថយដល់ការចំណាយសរុបថ្លៃដើមនៃការធ្វើជំនួញ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍបែបនេះ បានផ្តល់នូវកម្លាំងចលករក្នុងការបង្កើតអាជីវកម្មថ្មី ពង្រីកមូលដ្ឋានទីផ្សារមានស្រាប់ លើកទឹកចិត្តដល់យុទ្ធសាស្ត្រក្នុងការបញ្ជាក់ប្រភពដើមនៃទំនិញ និងសេវាកម្មក្នុងតំបន់ ព្រមទាំងបង្កើតការងារល្អៗជាបន្តបន្ទាប់។

ក្នុងនោះផងដែរ វិនិយោគិន និងធុរជនអាចទទួលបាន ៖

- ក្រុមហ៊ុនព័ត៌មានវិទ្យា ក្នុងប្រទេសអាស៊ានដែលមានចំណូលខ្ពស់ អាចផ្ទេរបច្ចេកវិទ្យាកម្មសិទ្ធិមុន ដោយគ្មានហានិភ័យពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- សហគ្រាសធុនតូច និងមធ្យម ក្នុងឧស្សាហកម្មច្នៃប្រឌិតអាចប្រើប្រាស់ហិរញ្ញប្បទានការច្នៃប្រឌិត ពាក់ព័ន្ធនឹងសិល្បៈ និងវប្បធម៌របស់ពួកគេ ក្នុងគោលដៅធ្វើឲ្យកើនឡើងនូវការធ្វើពាណិជ្ជូបនីយកម្ម

- ការវិនិយោគក្នុងអាស៊ាន អាចភ្ជាប់ទំនាក់ទំនងងាយស្រួលជាមួយបណ្តាប្រទេសជិតខាង អាស៊ីប៉ាស៊ីហ្វិក និងអាស៊ីពៀសាន និងអាគ្នេយ៍ តាមរយៈការធ្វើសមាហរណកម្មបណ្តាញដឹកជញ្ជូនរបស់តំបន់ (ឧទា៖ បណ្តាញរថភ្លើងពីសឹង្ហបុរី និងគុនមីង)
- ការវិនិយោគពឹងផ្អែកលើថាមពល ដូចជារោងចក្រផលិតទាំងនោះ រំពឹងថានឹងមានសុវត្ថិភាព និរន្តរភាព និងថ្លៃដើមទាបជាងមុន នៅពេលបង្កើតបំពង់បង្ហូរឧស្ម័នពាសពេញអាស៊ាន និងអភិវឌ្ឍន៍បណ្តាញថាមពលអាស៊ាន
- វិស័យឯកជននឹងត្រូវបានបង្កើនឱកាស ពាក់ព័ន្ធនឹងវិស័យថាមពល និងរ៉ែ ចំពោះការវិនិយោគហិរញ្ញប្បទាន និងការផ្ទេរបច្ចេកវិទ្យា។

## "គោលដៅនៃសហគមន៍សេដ្ឋកិច្ចអាស៊ានត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ"

**សសរស្តម្ភទីបី៖** ប្តេជ្ញាសម្រេចឲ្យបាននូវចីរភាព គុណភាពកំណើន និងអភិវឌ្ឍន៍ តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចប្រកបសមភាព។ ទាំងនេះបានមកពី ការផ្តួចផ្តើមគំនិតថ្មីៗប្រឌិត ដែលបានលើកទឹកចិត្តដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យចូលរួមក្នុងខ្សែសង្វាក់តម្លៃទាំងក្នុងតំបន់ និងសកល និងបានយកចិត្តទុកដាក់ខ្ពស់ លើកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាពនៃរដ្ឋជាសមាជិកថ្មីៗរបស់អាស៊ាន ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ច។

ជាមួយគ្នានេះ អ្នកវិនិយោគ និងធុរជន រំពឹងថានឹងមានការចូលរួមយ៉ាងខ្លាំងក្លាពី SMEs ក្នុងការកសាងបណ្តាញផលិតកម្មតំបន់ ដែលធានាឲ្យមាននូវជម្រើសទូលំទូលាយសម្រាប់អ្នកផ្គត់ផ្គង់ និងដៃគូនានាដែលគាំទ្រឧស្សាហកម្ម។ វិនិយោគិន និងធុរជន ក៏អាចទទួលបាននូវអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមធ្វើសមាហរណកម្មអាស៊ាន ក្នុងនាមជាអ្នកទទួលបាននូវផលប្រយោជន៍ពីរដ្ឋាភិបាលអាស៊ាន និងពង្រឹងសមត្ថភាពបន្ថែមទៀតនូវការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចដែលបន្តជំរុញផលប៉ះពាល់ជាវិជ្ជមាន នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

**សសរស្តម្ភចុងក្រោយទីបួន៖** សម្រេចឲ្យបាននូវចក្ខុវិស័យឆ្ពោះទៅការធ្វើសមាហរណកម្មពេញលេញនៃសហគមន៍សេដ្ឋកិច្ចអាស៊ានទៅក្នុងសេដ្ឋកិច្ចសកល។ ទាំងនេះត្រូវសម្រេចបានជាបន្តបន្ទាប់ តាមរយៈ

វិធីសាស្ត្រច្បាស់លាស់ ឆ្ពោះទៅការភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ចក្រៅតំបន់ រួមបញ្ចូលទាំងតំបន់ពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ និងបង្កើនការចូលរួមក្នុងបណ្តាញផ្គត់ផ្គង់ជាសកល។

ចំណែកវិនិយោគិន និងធុរជន ក៏អាចត្រូវបានធានាថា តំបន់នេះនៅតែបន្តតាមដាន និងពិនិត្យឡើងវិញនូវការអនុវត្តលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយទៅនឹងផ្នែកដែលពាក់ព័ន្ធ ក្នុងគោលដៅអនុញ្ញាតឱ្យអាជីវកម្មរបស់អាស៊ានបានជ្រៀតចូល និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកលប្រកបដោយភាពពេញលេញ។[3]

## ៥. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (The ASEAN Free Trade Area "AFTA")




[3] ការវិនិយោគក្នុងអាស៊ាន

បច្ចុប្បន្ន ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជាតំបន់ពាណិជ្ជកម្មសេរី។ ភាគីហត្ថលេខីដំបូងទាំង៦ (ព្រះរាជាណាចក្រប្រ៊ុយណេយដារូសាឡឹម, សាធារណរដ្ឋឥណ្ឌូណេស៊ី សហព័ន្ធម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៍) តម្រូវឲ្យអនុវត្តគម្រោងប្រព័ន្ធអនុគ្រោះពន្ធគយទូទៅ សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានមុនគេ ដើម្បីកាត់បន្ថយពន្ធគយលើពាណិជ្ជកម្មក្នុងតំបន់ មិនឲ្យលើសពី៥% (ប្រាំភាគរយ) លើផលិតផលស្ទើគ្រប់មុខ ដែលមានក្នុងបញ្ជីមុខទំនិញរួម ឬលុបចោលទាំងស្រុងលើពន្ធគយ។




គួររំឭកឡើងវិញ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន គឺត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ១៩៩២ ក្នុងគោលបំណងលុបបំបាត់របាំងពន្ធគយ លើបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ដោយពិនិត្យមើលលើ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ទៅជាមូលដ្ឋានផលិតកម្មតែមួយ និងបង្កើតទីផ្សារក្នុងតំបន់ សម្រាប់ប្រជាជនចំនួន ៦៣៤.៥លាននាក់។ កិច្ចព្រមព្រៀងស្តីពី គម្រោងអនុគ្រោះពន្ធគយប្រកបដោយប្រសិទ្ធភាព (CEPT) សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន តម្រូវឲ្យកំណត់អត្រាពន្ធក្នុងការកាត់បន្ថយពន្ធគយ

មិនឲ្យលើសពី៥% (ប្រាំភាគរយ) លើចំណាត់ថ្នាក់ផលិតផលដែលបានចរាចរក្នុងតំបន់ រីឯការរឹតត្បិតបរិមាណ និងរបាំងមិនមែនពន្ធគយដទៃទៀតវិញ ក៏នឹងត្រូវលុបបំបាត់។ តាមពេលវេលាដែលបានកំណត់បានឲ្យដឹងថា នៅឆ្នាំ២០០៨ គោលដៅនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ានគឺត្រូវបន្តទៅមុខឥតឈប់ឈរ។

ការលុបបំបាត់របាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ ក្នុងចំណោមសមាជិកអាស៊ាន ត្រូវបានដើរតួនាទីជាកាតាលីករជំរុញឲ្យមានប្រសិទ្ធភាពផលិតកម្ម និងការប្រកួតប្រជែង។ បន្ថែមពីនេះ ការកាត់បន្ថយរបាំងពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ផ្តល់ឲ្យអ្នកប្រើប្រាស់នូវជម្រើសសម្បូរបែបលើគុណភាពដ៏ប្រសើរដល់អ្នកប្រើប្រាស់ផលិតផល។ ចាប់តាំងពីឆ្នាំ២០០២មក មានតែទំនិញប្រមាណ៣.៨% ស្មើនឹង ១,៦៨៣មុខ លើ៤៤,០៦០មុខប៉ុណ្ណោះ នៃផលិតផលដែលមានក្នុងបញ្ជីទំនិញរួមនៃCEPT នៃភាគីហត្ថលេខីទាំង៦ដំបូង នៅគិតពន្ធលើស៥%។ ប្រទេសជាសមាជិកទាំង០៦ រួមមាន ប្រទេសឥណ្ឌូណេស៊ី ប្រ៊ុយណេយដារូសាឡឹម ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងប្រទេសថៃ ត្រូវបានអនុវត្តកិច្ចព្រមព្រៀង CEPT នៅឆ្នាំ២០០២ ហើយប្រទេសចំនួន០៤ទៀតត្រូវបានអនុគ្រោះដល់ការអនុវត្តនាឆ្នាំ២០០៦ សម្រាប់ប្រទេសវៀតណាមបានអនុវត្ត រីឯប្រទេសឡាវ និងមីយ៉ាន់ម៉ា អនុវត្តឆ្នាំ២០០៨ និងប្រទេសកម្ពុជាអនុវត្តក្រោយគេនៅឆ្នាំ២០១០។

តំបន់ពាណិជ្ជកម្មសេរីបានគ្របដណ្តប់លើគ្រប់ផលិតផលកសិកម្ម និងផលិតផលនានា បញ្ជីលើកលែងទូទៅចំនួន ៧៣៤បន្ទាត់ពន្ធគយ គឺត្រូវបានដកចេញជាអចិន្ត្រៃយ៍ពីកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី ផ្អែកលើហេតុផលដូចជា សន្តិសុខជាតិ ការការពារនៃមនុស្សជាតិ ជីវិតសត្វពាហនៈ ឬរុក្ខជាតិ សុខភាព កេរដំណែលសិល្បៈ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា ដែលស្មើនឹង ១.០៩ ភាគរយ នៃបន្ទាត់ពន្ធគយសរុបក្នុងសហគមន៍អាស៊ាន។[4]

[4] ទិដ្ឋភាពទូទៅនៃតំបន់ពាណិជ្ជកម្មសេរី - Overview of FTA

## ៥.១. ការផ្តួចផ្តើមគំនិតសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម

ASEAN បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់ ដោយផ្តោតសំខាន់លើពន្ធគយ និងការលុបបំបាត់របាំងបច្ចេកទេសពាណិជ្ជកម្ម ធ្វើយ៉ាងណាឲ្យថ្លៃដើមទាបក្នុងការធ្វើពាណិជ្ជកម្មក្នុងតំបន់។ កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ត្រូវបានផ្តល់ភាពងាយស្រួល និងសុខដុមនីយកម្មនៃនីតិវិធីគយ ជាពិសេសតាមរយៈវិធានការផ្សេងៗរួមមាន៖ ការធ្វើឲ្យមានសុខដុមភាពនូវមុខទំនិញរួចពន្ធគយ និងបានពន្លឿនការអនុវត្តកិច្ចព្រមព្រៀងវាយតម្លៃពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO Valuation Agreement)។ សហគមន៍សេដ្ឋកិច្ចអាស៊ានបានអនុម័តរួចរាល់ លើការធ្វើឲ្យមានសុខដុមនីយកម្មនៃមុខទំនិញរួចពន្ធគយក្នុងអាស៊ាន។

អាស៊ាន កំពុងខិតខំរៀបចំឲ្យមានការទទួលស្គាល់រវាងគ្នា និងគ្នាជារួម លើការវាយតម្លៃផលិតផលជាក់លាក់ ដូច្នេះបទបញ្ញត្តិ និងស្តង់ដារនានារបស់ផលិតផលពាក់ព័ន្ធ នឹងមិនក្លាយជារបាំងបច្ចេកទេសពាណិជ្ជកម្មបន្តទៀត។ ហើយគ្រឿងបរិក្ខាទូរគមនាគមន៍ ក៏ត្រូវបានលើកឡើងឲ្យមានការទទួលស្គាល់ទៅវិញទៅមករួចដែរ។ ការចរចា ក៏កំពុងបន្តនីតិវិធីបន្ថែមទៀតនៅក្នុងតំបន់ លើផលិតផលគ្រឿងសម្អាងវេជ្ជសាស្ត្រ អគ្គីសនី និងអេឡិចត្រូនិក បន្ថែមពីនេះ អាស៊ានបានព្រមព្រៀងលើការធ្វើសុខដុមនីយកម្មរវាងស្តង់ដារជាតិ ជាមួយស្តង់ដារអន្តរជាតិ ដូចជាអង្គការស្តង់ដារអន្តរជាតិ (ISO) គណៈកម្មាធិការបច្ចេកវិទ្យាអេឡិចត្រូនិកអន្តរជាតិ (IEU) និងសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) សម្រាប់ក្រុមផលិតផលអាទិភាព ២០មុខ។

ក្រុមនៃផលិតផលទាំង២០មុខនោះ សំដៅលើផលិតផលដែលកំពុងចរាចរយ៉ាងទូលំទូលាយបំផុតនៅក្នុងតំបន់ ដោយរួមបញ្ចូលទាំងទំនិញប្រើប្រាស់រយៈពេលវែង ដូចជា វិទ្យុ ឈុតនៃទូរទស្សន៍ ទូរទឹកកក ម៉ាស៊ីនត្រជាក់ និងទូរស័ព្ទ បន្ថែមពីលើក្រុមផលិតផលទាំង២០មុខនោះ អាស៊ានក៏បានធ្វើឲ្យស៊ីគ្នាទៅនឹងស្តង់ដារសុវត្ថិភាពចំនួន៧២ និងស្តង់ដារអេឡិកត្រូម៉ាញេទិចទាំង១០ ផ្សេងទៀត។



## ៥.២. ការរៀបចំពាណិជ្ជកម្មផ្អែកលើបទបញ្ញត្តិ

អាស៊ានបានអនុម័តយន្តការដោះស្រាយវិវាទ (ភាគច្រើនអនុលោមតាមការយោគយល់គ្នាដោះស្រាយវិវាទរបស់អង្គការ WTO) ដែលមានវិសាលភាពគ្របដណ្តប់លើកិច្ចព្រមព្រៀងសេដ្ឋកិច្ចទាំងអស់។ ការដាក់ចេញនូវយន្តការខាងលើនេះ គឺសម្រាប់ដោះស្រាយបញ្ហាមួយចំនួនដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងសេដ្ឋកិច្ចខ្លះៗក្នុងតំបន់។ បទបញ្ញត្តិ ស្តីពីការចាត់វិធានការបន្ទាន់ ក្រោមកិច្ចព្រមព្រៀង CEPT ត្រូវបានពង្រឹងដើម្បីធ្វើឲ្យសមស្របជាមួយនឹងកិច្ចព្រមព្រៀង WTO ស្តីពី ការចាត់វិធានការការពារ។ ពិធីសារមួយ ស្តីពីនីតិវិធីជូនដំណឹង ក៏ត្រូវបានដាក់ចេញដែលតម្រូវឲ្យមានការជូនដំណឹងជាមុន លើសកម្មភាព ឬការចាត់វិធានការណាមួយ ដែលអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើការផ្តល់ឧបត្ថម្ភសម្បទាន ក្រោមកិច្ចព្រមព្រៀងអាស៊ានដែលមានស្រាប់។ បន្ថែមពីនេះក៏បានព្រមព្រៀងលើពិធីសារទាក់ទងនឹងការអនុវត្តគម្រោងCEPT លើបញ្ជីលើកលែងបណ្តោះអាសន្ន ដែលមានបំណងផ្តល់ភាពបត់បែនដល់ប្រទេសដែលកំពុងជួបប្រទះនូវបញ្ហាប្រឈម លើវិធីសាស្ត្រដោះស្រាយចុងក្រោយនៃផលិតផលដែលបានផលិតក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន។ ពិធីសារនេះ ក៏បានអនុញ្ញាតឲ្យប្រទេសទាំងអស់ពន្យាពេលបណ្តោះអាសន្ន ក្នុងការផ្ទេរផលិតផលបញ្ជីលើកលែងបណ្តោះអាសន្ន ឬផ្អាកការផ្តល់លើផលិតផលក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន ដែលផ្ទេររួចរាល់ទៅក្នុងបញ្ជីរួម (Inclusion List)។

## ៥.៣. គោលដៅចុងក្រោយនៃ AFTA៖ ផ្តោតលើការលុបពន្ធនាំចូលទាំងអស់

ថ្នាក់ដឹកនាំអាស៊ាន បានព្រមព្រៀងលើការលុបបំបាត់ទាំងស្រុងលើពន្ធនាំចូល នៅឆ្នាំ២០១០ សម្រាប់រដ្ឋជាសមាជិកស្ថាបនិកអាស៊ាន ទាំង ៦ប្រទេស និងឆ្នាំ២០១៥ សម្រាប់សមាជិកថ្មី ៤ផ្សេងទៀត។ កន្លងទៅនេះ បន្ទាត់ពន្ធគយចំនួន ២០,៧០១ ស្មើនឹង ៣៨ភាគរយនៃបញ្ជីរួម គឺត្រូវបានលុបពន្ធទាំងស្រុង ដោយរំឮកកាលពីឆ្នាំ២០០៣ គឺប្រទេសសហស្ថាបនិកនីមួយៗចំនួន ៦ ត្រូវអនុវត្តការលុបពន្ធឲ្យបានត្រឹម ៦០ភាគរយនៃបញ្ជីរួម និងដោយឡែកប្រទេសជាសមាជិក ៤ផ្សេងទៀតរួមមាន ប្រទេសវៀតណាមត្រូវអនុវត្តការលុបពន្ធនៅឆ្នាំ២០០៦ ចំនួន ៣៥.៣៧ភាគរយនៃបញ្ជីរួម ខណៈពេលដែលប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា កាលពីឆ្នាំ២០០៨ បានលុបពន្ធនាំចូលចំនួន ៨៧.៦ភាគរយ និងមានចំនួន ៣.៩ភាគរយជាបន្តបន្ទាប់នៃបញ្ជីរួម រីឯប្រទេសកម្ពុជា ក៏បានលុបចោលពន្ធគយ ចំនួន ៧.៦៤ភាគរយ ក្នុងបញ្ជីរួមផងដែរ។[5]

## ៥.៤. ការតភ្ជាប់សេដ្ឋកិច្ចក្រៅតំបន់



[5] តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

ការសម្រេចបាននូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ដែលពោរពេញទៅដោយសារៈប្រយោជន៍ដល់ដៃគូសេដ្ឋកិច្ចអាស៊ាន គឺត្រូវបានរកដំណោះស្រាយក្នុងការជំរុញការតភ្ជាប់សេដ្ឋកិច្ច តាមបណ្តាប្រទេសអាស៊ីបូព៌ាឆ្ពោះទៅកាន់ការធ្វើសមាហរណកម្មតំបន់អាស៊ាន ជាមួយប្រទេសចិន ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង ដែលបានសម្រេចជារួមដោយមេដឹកនាំប្រទេសអាស៊ាន ក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងបង់ដាសេរីបេហ្គាវ៉ាន់ កាលពីថ្ងៃទី៥-៦ខែវិច្ឆិកា ឆ្នាំ២០០១។

មេដឹកនាំអាស៊ាន និងចិន បានពិចារណាលើរបាយការណ៍របស់ក្រុមជំនាញការអាស៊ាន-ចិន លើកិច្ចប្រតិបត្តិការសេដ្ឋកិច្ច នៅក្នុងកិច្ចប្រជុំនាប្រទេសសឹង្ហបុរី។ មេដឹកនាំអាស៊ាន-ចិនគាំទ្រនូវសំណើសម្រាប់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបានព្រមព្រៀងបង្កើតនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន រយៈពេល១០ឆ្នាំ ជាមួយនឹងប្រព្រឹត្តកម្មផ្សេងៗ ជាពិសេសសម្រាប់សមាជិកអាស៊ានថ្មីៗ។

ក្រៅពីនេះ អាស៊ានកំពុងចរចា ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសដៃគូសន្ទនារបស់ខ្លួនរួមមានៈ

- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN - China FTA) នៅឆ្នាំ២០១០ សម្រាប់សមាជិកទាំង៦ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) និងឆ្នាំ២០១៥ សម្រាប់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។
- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន (ASEAN-Japan FTA) នៅឆ្នាំ២០១២ សម្រាប់សមាជិកទាំង៦ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) ហើយ៤ប្រទេសទៀតនៅឆ្នាំ២០១៧មាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។
- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (ASEAN - Korea FTA) នៅឆ្នាំ២០១០ សម្រាប់សមាជិកទាំង៦ប្រទេសរបស់អាស៊ានមាន (ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍) ជាមួយវៀតណាមនៅឆ្នាំ២០១៦ និងជាមួយកម្ពុជា ឡាវ មីយ៉ាន់ម៉ា នៅឆ្នាំ២០១៨។

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេដ្ឋកិច្ចជិតស្និទ្ធនៃប្រទេសអូស្ត្រាលី ញូហ្សីឡែន ត្រូវបានរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះកាលពីឆ្នាំ២០០២ (Australia - New Zealand closer Economic Relations Trade Agreement - CER) និងសេចក្តីថ្លែងការថ្នាក់រដ្ឋមន្ត្រីស្តីពី Ministerial Declaration on FTA-CER។

## ៦. វឌ្ឍនភាពនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន






បណ្ដាប្រទេសនៅក្នុង និងក្រៅតំបន់អាស៊ីតែងវាយតម្លៃខ្ពស់ និងចាត់ទុកវេទិកានានាដែលដឹកនាំដោយអាស៊ាន ថាជាវេទិកាដែលទុកចិត្តបានក្នុងការលើកឡើងពីបញ្ហាកង្វល់ និងបញ្ហាប្រឈមរួម។ នីតិវិធីរបស់អាស៊ានដែលតែងតែស្វែងរកការសន្ទនា ការពិគ្រោះយោបល់ និងការចូលរួម គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់តំបន់។ លិខិតូបករណ៍សំខាន់ៗដូចជា សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ីអាគ្នេយ៍ (TAC) និងសេចក្ដីថ្លែងការណ៍ស្ដីពីការប្រតិបត្តិការរបស់បណ្ដាភាគីនៅសមុទ្រចិនខាងត្បូង (DOC) ជាដើម។ អាស៊ានបានផ្ដួចផ្ដើម និងថែរក្សាយ៉ាងប្រុងប្រយ័ត្ននូវនិម្មាបនកម្មតំបន់សំខាន់ៗជាច្រើន ដែលបានរក្សាឲ្យតំបន់មានស្ថិរភាព និងវិបុលភាព ជាក់ស្ដែងដូចជាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន វេទិកាតំបន់អាស៊ាន អាស៊ានបូកបី កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងកិច្ចប្រជុំការពារជាតិបូកជាដើម។

ប្រសិនបើយើងចាត់ទុកសហគមន៍សេដ្ឋកិច្ចអាស៊ាន AEC ជាប្រទេសមួយនោះ AEC ត្រូវបានជាប់ចំណាត់ថ្នាក់ថាជាប្រទេសដែលមានទំហំសេដ្ឋកិច្ចធំទីបីនៅអាស៊ី និងជាគ្រឹះស្ថានសេដ្ឋកិច្ចពាណិជ្ជកម្មសកលដ៏មានឥទ្ធិពលមួយ ដែលឈរលំដាប់ទីប្រាំមួយនៅលើពិភពលោក។ កាលពីឆ្នាំ២០១៧កន្លងទៅ ទំហំពាណិជ្ជកម្មសរុបរបស់អាស៊ានមានចំនួន ២,៦២៩.៩ពាន់លានដុល្លារសហរដ្ឋអាមេរិក ជាមួយនឹងកំណើន GDP ៤.៨ភាគរយនៅក្នុងឆ្នាំ២០១៦ ព្រមទាំងទទួលបានការវិនិយោគដោយផ្ទាល់ពីបរទេសចំនួន៩៨.០៤ពាន់លានដុល្លារសហរដ្ឋអាមេរិក និងទទួលបានភ្ញៀវទេសចរណ៍ជាង១០០លាននាក់ផងដែរ។

វឌ្ឍនភាពបន្តត្រូវបានបង្កើតឡើងសម្រាប់ការអនុវត្តក្នុងផែនការមេ នៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥។ ជាពិសេសត្រឹមឆ្នាំ២០១៧កន្លងទៅនេះ ក្រោមប្រធានបទ**ការរីកលូតលាស់នៃការជំរុញនវានុវត្តន៍ និងបរិយាប័ន្ន** បានទទួលនូវវឌ្ឍនភាព និងសមិទ្ធផលដូចជា៖

- ***គម្រោងចេញវិញ្ញាបនបត្របញ្ជាក់ដោយខ្លួនឯងរបស់អាស៊ាន៖*** គម្រោងនេះនឹងជួយសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានលើទំនិញ ដោយអនុញ្ញាតឲ្យអ្នកនាំចេញ

ចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើម និងកាត់បន្ថយថ្លៃដើមប្រតិបត្តិការ។ រដ្ឋជាសមាជិកអាស៊ាន (AMS) កំពុងតែពន្លឿនការងារ ក្នុងការអនុវត្តឆ្ពោះទៅកាន់គម្រោងចេញវិញ្ញាបនបត្របញ្ជាក់ដោយខ្លួនឯងរបស់អាស៊ាននៅឆ្នាំ២០១៨។

- ***សូចនាករនៃកិច្ចសម្រួលពាណិជ្ជកម្មឲ្យមានភាពរលូនក្នុងអាស៊ាន (ASTFI)*៖** រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) បានអនុម័ត ASTFI ដើម្បីវាស់វែងនិងតាមដាននូវការពន្យាពេល ចំពោះវិធានការនៃកិច្ចសម្រួលពាណិជ្ជកម្ម ដែលបានអនុវត្តក្នុងតំបន់ តាមរយៈកិច្ចព្រមព្រៀងអាស៊ាន និងផែនការការងារលើវិស័យផ្សេងៗពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្ម។ AEM ត្រូវបានអនុម័តលើផែនការសកម្មភាពយុទ្ធសាស្ត្រនៃកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ឆ្នាំ២០២៥ ស្របតាមASTFI (ATF-SAP)។ ATF-SAP និង ASTFI មានសារៈសំខាន់ក្នុងការសម្រេច និងតាមដាននូវការកំណត់គោលដៅនៃកិច្ចសម្រួលពាណិជ្ជកម្មសំខាន់ៗចំនួន២ គឺការកាត់បន្ថយថ្លៃដើមប្រតិបត្តិការពាណិជ្ជកម្មក្នុងតំបន់ចំនួន ១០% នៅឆ្នាំ២០២០ និងការធ្វើពាណិជ្ជកម្មក្នុងអាស៊ានឲ្យកើនឡើងទ្វេដង ចន្លោះឆ្នាំ២០១៧ និង២០២៥។
- ***កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានលើសេវាកម្ម (ATISA)*** ៖ មានលក្ខណៈទូលំទូលាយ និងជាលិខិតតូបករណ៍សម្រាប់ការធ្វើសមាហរណកម្មបន្ថែមទៀត លើវិស័យសេវាកម្មក្នុងអាស៊ាន។ កិច្ចចរចារសម្រាប់ ATISA បានរំពឹងថានឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៧។
- ***របៀបវារៈសកម្មភាពយុទ្ធសាស្ត្រ ដែលត្រូវផ្តោត (FAST)លើការវិនិយោគ*** ៖ របៀបវារៈ FAST ត្រូវបានអនុវត្តតាមរយៈគំនិតផ្តួចផ្តើមមួយចំនួន ស្របនឹងសសរស្តម្ភទាំង៤នៃកិច្ចព្រមព្រៀងវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន ដូចជាសេរីភាវូបនីយកម្ម ការជំរុញ កិច្ចសម្រួល និងការការពារការវិនិយោគ ដោយរួមបញ្ចូលទាំងការរៀបចំសកម្មភាពជំនួបពាណិជ្ជកម្មមួយ រវាងក្រុមហ៊ុនពហុភាគី និងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យមកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ ក្នុងទីក្រុងម៉ានីលប្រទេសហ្វីលីពីន។

- ***យន្តការត្រួតពិនិត្យឡើងវិញសម្រាប់ AEC៖*** យន្តការត្រួតពិនិត្យឡើងវិញសម្រាប់ AEC ត្រូវបានធ្វើឡើងតាមរយៈដំណើរទស្សនកិច្ចផ្លូវការ ដែលជាឧបករណ៍ត្រួតពិនិត្យបច្ចេកទេស សម្រាប់តាមដានអនុលោមភាពនៃក្របខ័ណ្ឌវាយតម្លៃ និងត្រួតពិនិត្យសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥។ ដំណើរទស្សនកិច្ចជាផ្លូវការលើកដំបូង ត្រូវបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៩-១៣ ខែតុលា ឆ្នាំ២០១៧ នៅប្រទេសហ្វីលីពីន រីឯលើកទី២ នៅប្រទេសឥណ្ឌូណេស៊ី កាលពីចុងឆ្នាំ២០១៧។
- ***ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ (RCEP)*** ៖ បច្ចុប្បន្ន កិច្ចចរចាលើកទី២០ ត្រូវបានរៀបចំឡើង។ កាលពីកិច្ចប្រជុំលើកទី១៩ គណៈកម្មាធិការចរចាពាណិជ្ជកម្ម RCEP បានព្រមព្រៀងគ្នាស្តីពី "សមាសធាតុគន្លឹះក្នុង RCEP សម្រាប់លទ្ធផលសំខាន់នៅចុងឆ្នាំ២០១៧" ។ កិច្ចប្រជុំលើកទី២០ រដ្ឋមន្ត្រីទាំងអស់បានណែនាំដល់ អ្នកចរចាឲ្យខិតខំប្រឹងប្រែងចរចា ដើម្បីសម្រេចបាននូវលទ្ធផល ដូចមានចែងក្នុងកំណត់ហេតុ។ ប្រទេសដែលចូលរួម RCEP ទាំងអស់នៅតែបន្តប្តេជ្ញាបញ្ចប់ឲ្យបានរហ័សដូចការកំណត់របស់ថ្នាក់ដឹកនាំ ហើយកិច្ចប្រជុំ RCEP នឹងត្រូវបានធ្វើឡើងស្របគ្នានឹងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១។
- ***កម្មវិធីការងារអាស៊ាន ស្តីពី ពាណិជ្ជកម្មតាមអេឡិចត្រូនិច (AWPEC) ២០១៧-២០២៥*** ៖ AWPEC ត្រូវបានបញ្ចប់ ដោយបានបង្កើតនូវគណៈកម្មាធិការសម្របសម្រួលអាស៊ាន លើពាណិជ្ជកម្មតាមអេឡិចត្រូនិច (E-Commerce) និងបានអនុម័ត ដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) កាលពីខែកញ្ញា ឆ្នាំ២០១៧។ AWPEC មានគោលបំណងដើម្បីជួយសម្រួលពាណិជ្ជកម្មតាមអេឡិចត្រូនិចឆ្លងកាត់ព្រំដែនក្នុងអាស៊ាន ដោយគ្របដណ្តប់លើគំនិតផ្តួចផ្តើមពាណិជ្ជកម្មតាមអេឡិចត្រូនិចលើពហុវិស័យ ដូចជាវិស័យហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងសមត្ថភាពបច្ចេកវិទ្យា កិច្ចការពារអ្នកប្រើប្រាស់ ទំនើបភាវូបនីយកម្មនៃក្របខ័ណ្ឌច្បាប់ សុវត្ថិភាពនៃប្រតិបត្តិការអេឡិចត្រូនិច ប្រព័ន្ធទូទាត់ កិច្ចសម្រួលពាណិជ្ជកម្ម ការប្រកួតប្រជែង និងប្រព័ន្ធ

ភ័ស្តុភារ។ គន្លឹះសំខាន់សម្រាប់ AWPEC គឺដើម្បីអភិវឌ្ឍកិច្ចព្រមព្រៀងអាស៊ានស្តីពី ពាណិជ្ជកម្មតាមអេឡិចត្រូនិច។

- ***បរិយាប័ន្នពាណិជ្ជកម្ម (IB)*** ៖ ក្របខណ្ឌ IB អាស៊ាន ត្រូវបានចុះហត្ថលេខាព្រមព្រៀងដោយ AEM ក្នុងខែកញ្ញា ឆ្នាំ២០១៧។ គំនិតផ្តួចផ្តើម IB នៃប្រទេសហ្វីលីពីន បានផ្អែកលើក្របខណ្ឌ G20 ដែលជំរុញការអនុម័តនូវគំរូពាណិជ្ជកម្ម ដែលផ្តល់នូវ ទំនិញ សេវាកម្ម និងជីវភាពរស់នៅឈរលើមូលដ្ឋានរកប្រាក់ចំណេញដល់ប្រជាពលរដ្ឋ។
- ***ការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី*** ៖ សេចក្តីថ្លែងការក្រុងម៉ានីល ស្តីពីអានុភាពនៃការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងអាស៊ាន រួមមានរបៀបវារៈ៦ចំណុច ដែលបានឯកភាពគ្នាដោយ AEM ក្នុងខែកញ្ញា ឆ្នាំ២០១៧ ដើម្បីស្នើសុំការអនុម័តនៅក្នុងកិច្ចប្រជុំមេដឹកនាំ នាខែវិច្ឆិកា ឆ្នាំ២០១៧។
- ***សេចក្តីប្រកាសអាស៊ាន ស្តីពី ការច្នៃប្រឌិត*** ៖ រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាស៊ាន បានព្រមព្រៀងចុះហត្ថលេខា លើសេចក្តីប្រកាសសម្រាប់មេដឹកនាំអាស៊ាន និងត្រូវបានអនុម័តក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។ សេចក្តីប្រកាសនេះ បានបញ្ជាក់ពីការប្តេជ្ញារបស់អាស៊ាន ដើម្បីឆ្ពោះទៅកាន់ការពង្រឹងនូវផលប៉ះពាល់នៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការច្នៃប្រឌិត និងឆ្ពោះទៅពង្រឹងសិទ្ធិរបស់ប្រជាពលរដ្ឋ ការរីកចម្រើនប្រកបដោយបរិយាប័ន្ន និងការពង្រឹងសហគមន៍អាស៊ាន។[6]

បន្ថែមពីអាទិភាពខាងលើ វិស័យផ្សេងៗទៀតក៏មានវឌ្ឍនភាពផងដែរក្នុង AEC ។ គោលការណ៍ណែនាំថ្នាក់តំបន់អាស៊ាន ស្តីពី គោលនយោបាយសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ ត្រូវបានចុះហត្ថលេខាព្រមព្រៀងគ្នានៅកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើ អាស៊ាន (AMAF) លើកទី៣៩ ក្នុងខែកញ្ញា ឆ្នាំ២០១៧។ គោលការណ៍ណែនាំនេះ បានដើរតួនាទីជាក្របខ័ណ្ឌទូទៅមួយដើម្បី

[6] សង្ខេបសមាហរណកម្ម និងបច្ចុប្បន្នភាពសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៧

ជួយ AMS ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភ និងការធ្វើសមាហរណកម្មក្នុងតំបន់ឲ្យកាន់តែខ្លាំងជាងមុន។ AMAF ក៏ត្រូវបានចុះហត្ថលេខាព្រមព្រៀងគ្នាលើក្របខ័ណ្ឌនានា និងឯកសារសំខាន់មួយចំនួន រួមមានក្របខ័ណ្ឌថ្នាក់តំបន់ក្នុងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនអាស៊ាន សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាក្នុងវិស័យ ម្ហូបអាហារ កសិកម្ម និងព្រៃឈើ ដោយកែតម្រូវនូវលក្ខខណ្ឌតម្រូវអាស៊ាន និងការចង្អុលបង្ហាញសម្រាប់ការគ្រប់គ្រងព្រៃឈើតំបន់ត្រូពិចប្រកបដោយចីរភាព ផែនការសកម្មភាពលើកិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពី ម្ហូបអាហារហាឡាល ឆ្នាំ២០១៧-២០២០ និង គោលការណែនាំអាស៊ាន ស្តីពីការប្រើប្រាស់ដោយប្រុងប្រយ័ត្នប្រឆាំងនឹងមេរោគនៅក្នុងសាច់សត្វ។

ចំពោះកិច្ចសហប្រតិបត្តិការរបស់អាស៊ានលើការដឹកជញ្ជូន លទ្ធផលសំខាន់មួយចំនួន ត្រូវបានប្រកាសនៅកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី២៣ ក្នុងខែតុលា ឆ្នាំ២០១៧។ ក្នុងផ្នែកមួយនៃការផ្តួចផ្តើមគំនិត បង្កើតទីផ្សារជើងហោះហើរតែមួយអាស៊ាន AMS បានបញ្ចប់លើកញ្ចប់ទី១០ ស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងអាស៊ាន ស្តីពីសេវាកម្ម និងចុះហត្ថលេខាលើពិធីសារដើម្បីជួយសម្រួលដល់ការអនុវត្ត។ រដ្ឋមន្ត្រីទាំងអស់ក៏បានចុះហត្ថលេខាលើពិធីសារទី៣ ស្តីពីកិច្ចសហការជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃ AMS ការអនុម័តលើផែនការមេក្នុងការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាសអាស៊ាន ការអនុម័ត និងចុះហត្ថលេខា ស្តីពីដំណើរការទទួលស្គាល់គ្នាទៅវិញទៅមកលើវិញ្ញាបនបត្របាហុនិកា។ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី កិច្ចសម្រួលការដឹកជញ្ជូនអ្នកដំណើរឆ្លងកាត់ព្រំដែនតាមយានយន្ត ក្របខ័ណ្ឌដឹកជញ្ជូនក្នុងតំបន់ដ៏សំខាន់ ត្រូវបានដាក់បញ្ចូល និងចុះហត្ថលេខា។

# អត្រាកំណើនផ.ស.ស ឆ្នាំ២០០៧-២០១៦

ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧ (គិតជា៖ ភាគរយ)

| ប្រទេស | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១០-២០១៦ |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រ៊ុយណេ | ០.៦ | -២.៤ | -១.៨ | ២.៦ | ៣.៧ | ០.៩ | -២.១ | -២.៥ | -០.៤ | -២.៥ | -០.៥ |
| កម្ពុជា | ១០.២ | ៦.៧ | ០.១ | ៦.០ | ៧.១ | ៧.៣ | ៧.៤ | ៧.១ | ៧.០ | ៦.៩ | ៧.១ |
| ឥណ្ឌូនេស៊ី | ៦.៣ | ៦.០ | ៤.៦ | ៦.២ | ៦.៥ | ៦.៣ | ៥.៦ | ៥.០ | ៤.៩ | ៥.០ | ៥.៥ |
| ឡាវ | ៦.០ | ៧.៨ | ៧.៥ | ៨.១ | ៨.០ | ៧.៩ | ៨.០ | ៧.៦ | ៧.៣ | ៧.០ | ៧.៦ |
| ម៉ាឡេស៊ី | ៦.៣ | ៤.៨ | -១.៥ | ៧.៤ | ៥.៣ | ៥.៥ | ៤.៧ | ៦.០ | ៥.០ | ៤.២ | ៥.១ |
| មីយ៉ាន់ម៉ា | ១២.០ | ១០.៣ | ១០.៥ | ៩.៦ | ៥.៦ | ៧.៣ | ៨.៤ | ៨.០ | ៧.០ | ៥.៧ | ៧.០ |
| ហ្វីលីពីន | ៦.៦ | ៤.២ | ១.១ | ៧.៦ | ៣.៧ | ៦.៧ | ៧.១ | ៦.២ | ៦.១ | ៦.៩ | ៦.១ |
| សឹង្ហបុរី | ៩.១ | ១.៨ | -០.៦ | ១៥.២ | ៦.២ | ៣.៩ | ៥.០ | ៣.៦ | ១.៩ | ២.០ | ៣.៨ |
| ថៃឡង់ដ៍ | ៥.៤ | ១.៧ | -០.៧ | ៧.៥ | ០.៨ | ៧.២ | ២.៧ | ០.៩ | ២.៩ | ៣.២ | ៣.០ |
| វៀតណាម | ៧.១ | ៥.៧ | ៥.៤ | ៦.៤ | ៦.២ | ៥.២ | ៥.៤ | ៦.០ | ៦.៧ | ៦.២ | ៦.០ |
| អាស៊ាន | ៦.៦ | ៤.៧ | ២.៥ | ៧.៥ | ៥.០ | ៦.២ | ៥.២ | ៤.៧ | ៤.៧ | ៤.៨ | ៥.១ |
| អាស៊ាន ៥ | ៦.៤ | ៤.៤ | ១.៩ | ៧.៦ | ៤.៩ | ៦.២ | ៥.០ | ៤.៤ | ៤.៥ | ៤.៦ | ៤.៩ |
| BCLMV | ៨.៣ | ៦.៧ | ៦.៣ | ៧.២ | ៦.១ | ៥.៩ | ៦.២ | ៦.៤ | ៦.៦ | ៥.៨ | ៦.២ |

# ពាណិជ្ជកម្មលើទំនិញ




ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧

## ពាណិជ្ជកម្មអាស៊ានលើទំនិញ ឆ្នាំ២០០៧-២០១៦




ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧



## ទំនិញនាំចេញ ទាំង១០មុខ ក្នុងឆ្នាំ២០១៦




ប្រភព៖ លេខាធិការដ្ឋានអាស៊ាន, គំនូសតាងAEC ឆ្នាំ២០១៧

## ទំនិញនាំចូល ទាំង១០មុខ ឆ្នាំ២០១៦




ប្រភព៖ លេខាធិការដ្ឋានអាស៊ាន, គំនូសតាងAEC ឆ្នាំ២០១៧

ការចាប់ផ្ដើមប្រតិបត្តិការផ្ទាល់នៅក្នុងបញ្ជរជាតិតែមួយASEAN single window-ASW នៃការផ្លាស់ប្ដូរទម្រង់ D (e-TIGA) របស់សមាជិកអាស៊ានទាំងប្រាំប្រទេស មានប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបុរី ថៃឡង់ដ៍ និងវៀតណាម ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ កន្លងមក ហើយពិធីសារនៃការអនុវត្ត "The 10th Package of commitments" ក្រោមកិច្ចព្រមព្រៀងអាស៊ាន ស្ដីពីសេវាកម្មនោះ ក៏នឹងត្រូវចុះហត្ថលេខាក្នុងឆ្នាំ២០១៨ នេះផងដែរ។ ចំពោះវឌ្ឍនភាពសំខាន់ៗនៃការចរចា

សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានលើសេវាកម្ម(ATISA) ក៏សង្ឃឹមថានឹងត្រូវចុះហត្ថលេខាក្នុងឆ្នាំដដែលនេះ។ ការទទួលស្គាល់នូវសារៈសំខាន់នៃយុគសម័យ Digital និងការលើកកម្ពស់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce) នៅក្នុងតំបន់បានបញ្ចប់ការចរចាលើកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងទន្ទឹងការរង់ចាំការចុះហត្ថលេខានៅឆ្នាំដដែលនេះ។ អាស៊ាន នៅតែបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំសហគមន៍សេដ្ឋកិច្ចអាស៊ាន AEC ឲ្យកាន់តែប្រសើរឡើងសម្រាប់យុគសម័យ Digital តាមរយៈការពង្រឹង និងការសម្របសម្រួលនៃការអនុវត្តការងារអាស៊ាន ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៧-២០២៥ ហើយអាស៊ានក៏ស្វាគមន៍ចំពោះការប្រកាសមេដឹកនាំនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ លើគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការស្តង់ដារពាណិជ្ជកម្ម Digital អាស៊ាន-អូស្ត្រាលីផងដែរ។

កិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ បានប្រារព្ធឡើងកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ នៅទីក្រុងសាំងហ្គាពួរ ប្រទេសសឹង្ហបុរី ក្រោមប្រធានបទ "**ការកសាងកាលានុវត្តន៍ និងភាពរឹងមាំរបស់អាស៊ាន**" ។ នៅក្នុងបរិបទនេះ សឹង្ហបុរី ចង់ឲ្យសមាជិកអាស៊ាន និងបណ្តាដៃគូសមាជិកអាស៊ាន មានការតភ្ជាប់រវាងប្រជាពលរដ្ឋប្រមាណ៦៣៤.៥លាននាក់ ផ្តល់ការងាយស្រួលដល់ការធ្វើដំណើរឆ្លងកាត់ព្រំដែន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា Digital និងការបង្កើតបណ្តាញទីក្រុងឆ្លាត នៅក្នុងបណ្តារដ្ឋសមាជិកអាស៊ាន ព្រមទាំងស្វាគមន៍នូវគំនិតផ្តួមផ្តើមនានា ដែលនឹងពង្រឹងដល់និម្មាបនកម្មតំបន់ដែលមានអាស៊ានជាកម្លាំងស្នូល ប្រកបដោយភាពបើកចំហ និងតម្លាភាព បរិយាប័ន្ន និងផ្អែកលើយន្តការនាំមុខដោយអាស៊ាន។ ទន្ទឹមនឹងនេះដែរ បណ្តាមេដឹកនាំអាស៊ាន បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ ក៏ដូចជាការដោះស្រាយជម្លោះដោយសន្តិវិធី ដោយរួមទាំងការគោរពដោយពេញលេញនូវដំណើរការផ្លូវច្បាប់

និងការទូត ដោយអនុលោមទៅតាមគោលការណ៍ជាសកលនៃច្បាប់អន្តរជាតិ ហើយក៏បានព្រមព្រៀង អនុម័តលើទស្សនវិស័យ ស្តីពី នវានុវត្តន៍ នៃភាពរឹងមាំរបស់អាស៊ាន ដោយបញ្ជាក់ពីគោលជំហរ និង បំណងប្រាថ្នារបស់អាស៊ានក្នុងរបត់ភូមិសាស្រ្តនយោបាយ និងសេដ្ឋកិច្ច ជាពិសេសបានឯកភាពគ្នា បង្កើតបណ្តាញទីក្រុងឆ្លាតអាស៊ាន និងបានអនុម័តលើសេចក្តីប្រកាសរួមអាស៊ាន ស្តីពី ទេសចរណ៍ តាមនាវា និងការទទួលស្គាល់នូវសន្ទុះនៃសមិទ្ធផលសេដ្ឋកិច្ចអាទិភាព សម្រាប់ឆ្នាំ២០១៨។ មេដឹកនាំ អាស៊ាន បានគាំទ្រគំនិតផ្តួចផ្តើមក្នុងការបង្កើតយន្តការសមាហរណកម្ម Digital អាស៊ាន ដើម្បីតាមដាន ដំណើរការនៃការធ្វើសមាហរណកម្ម Digital របស់អាស៊ាន និងសេចក្តីថ្លែងការទីក្រុងវៀងចន្ទន៍ លើ គំនិតផ្តួចផ្តើមរបស់យុវជនអាស៊ាន ស្តីពីផែនការសកម្មភាព ក្នុងការផ្លាស់ប្តូរការងារនៅក្រៅប្រព័ន្ធ ឲ្យក្លាយទៅជាការងារក្នុងប្រព័ន្ធដើម្បីលើកកម្ពស់ការងារសមរម្យរបស់អាស៊ាន។

វឌ្ឍនភាពនៃកិច្ចប្រជុំកំពូលនេះ ផែនការការងារទី៣ នៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI Work Plan III) ត្រូវបានអនុវត្តដើម្បីជួយដល់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ក្នុងការសម្រេចបាននូវគោលដៅដ៏ទូលំទូលាយរបស់អាស៊ាន និងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ នៅក្នុងអាស៊ាន។

## ៧. សហគមន៍អាស៊ាន និងដៃគូសន្ទនា

អាស៊ានបានបន្តលើកទឹកចិត្តយ៉ាងមុតមាំដល់វិស័យឯកជន ក៏ដូចជាដៃគូសន្ទនារបស់ខ្លួន ដើម្បី ដើរតួនាទីកាន់តែប្រសើរក្នុងការអភិវឌ្ឍទំនាក់ទំនង ប្រកបដោយអត្ថប្រយោជន៍។ ជាការពិតណាស់ វិស័យឯកជននៃភាគីទាំងពីរ បានឆ្លើយតបជាវិជ្ជមាន ដែលជាលទ្ធផលក្នុងការបង្កើតក្រុមប្រឹក្សាធុរកិច្ច រួមគ្នា រវាងអាស៊ាន និងគ្រប់ដៃគូសន្ទនារបស់ខ្លួន។ អ្នកតំណាងក្រុមប្រឹក្សាអាជីវកម្មនីមួយៗ តែងតែ ចូលរួមក្នុងការប្រជុំសន្ទនា ឬសន្និសីទរួមគ្នា ។




ទំនាក់ទំនងកិច្ចសន្ទនារបស់អាស៊ាន មិនផ្តោតតែលើបញ្ហាសេដ្ឋកិច្ចទេ ទោះបីជាពេលសន្និសីទកាសែតថ្នាក់រដ្ឋមន្ត្រី បានលើកឡើងនូវក្តីបារម្ភពីវិស័យនេះក៏ដោយ។ ចាប់តាំងពីកិច្ចប្រជុំកំពូលលើកទី៤ នៅក្នុងប្រទេសសឹង្ហបុរី ក៏បានពិភាក្សាអំពីបញ្ហាដែលជាកង្វល់រួម លើវិស័យសន្តិសុខពិភពលោក និងបញ្ហាអន្តរជាតិផ្សេងៗទៀត។ បន្ថែមពីនេះ អាស៊ានក៏បានផ្តោតការយកចិត្តទុកដាក់នៅលើកិច្ចសហប្រតិបត្តិការខាងនយោបាយ និងសន្តិសុខ (Political and Security Cooperation) ដោយឈរលើមូលដ្ឋានបង្កើតភូមិភាគអាស៊ីអាគ្នេយ៍ ជាតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត្យ (Zone of Peace, Freedom and Neutrality – ZOPFAN) និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation in Southeast Asia - TAC) អាស៊ានបានបង្កើតនូវយន្តការពិគ្រោះយោបល់ជាមួយដៃគូសន្ទនារួមមាន៖ សន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងវេទិកាតំបន់អាស៊ាន។

ខាងក្រោមនេះគឺជាព័ត៌មានសង្ខេបនៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន នីមួយៗៈ

**អាស៊ាន-អូស្ត្រាលី** កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-អូស្ត្រាលី (ASEAN-Australia Economic Cooperation Program - AAECP) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៤ ដោយបានគាំទ្រគម្រោងអាស៊ានក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា ប្រជាជន ការអប់រំ និងបណ្តុះបណ្តាល ការអភិវឌ្ឍសង្គម ការផ្លាស់ប្តូរវប្បធម៌ ការផ្សារភ្ជាប់ស្ថាប័ន និងកិច្ចសម្រួលពាណិជ្ជកម្ម។ កម្មវិធីផ្សារភ្ជាប់ AAECP មានបំណងជំរុញសកម្មភាពសហប្រតិបត្តិការដែលពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ស្រាវជ្រាវ អប់រំ និងវិស័យសាធារណៈ ក្នុងនោះរួមមានវិស័យគ្រប់គ្រងបរិស្ថាន ការដឹកជញ្ជូន ទូរគមនាគមន៍ ព័ត៌មានវិទ្យា ជីវសាស្ត្រ និងកសិ-ឧស្សាហកម្ម។ ក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន-អូស្ត្រាលី បានបង្កើតឡើង ដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងភាគីទាំងពីរ។ ទន្ទឹមនោះ អូស្ត្រាលី មានបំណងពង្រីក និងលើកកម្ពស់ បន្ថែមស្តីពីការតភ្ជាប់រវាងប្រជាជន និងប្រជាជន ឲ្យកាន់តែទូលំទូលាយ ដោយគាំទ្រដល់សិស្ស និស្សិតអូស្ត្រាលីមកសិក្សា និងអនុវត្តការងារនៅតាមបណ្តាប្រទេសអាស៊ាន ព្រមទាំងបង្កើនចំនួនអាហារូបករណ៍អូស្ត្រាលីទ្វេដងដល់ប្រទេសជាសមាជិកអាស៊ាន ដែលមានចំនួនសរុបជាង១៥០០កន្លែង ក្នុងឆ្នាំ២០១៧។

**អាស៊ាន-ញ៉ូវហ្សេឡែន** មានសកម្មភាពសហប្រតិបត្តិការរវាងគ្នា និងគ្នា ដោយចាប់ផ្តើមក្នុងឆ្នាំ១៩៧៥។ បច្ចុប្បន្ន គម្រោងជាច្រើនបានបញ្ចូលក្នុងការជំរុញនៃការផ្សារភ្ជាប់ស្ថាប័នថាមពល រួមមានការប្រើប្រាស់ហ្គាសធម្មជាតិក្នុងការដឹកជញ្ជូន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការគ្រប់គ្រងសារធាតុញៀនគ្រឿងញៀន (Narcotic Control) និងការអភិវឌ្ឍសង្គម។ ក្នុងចំណោមការអនុវត្តភាគច្រើន ក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន-ញ៉ូវហ្សេឡែន គឺជាកម្មវិធីផ្សារភ្ជាប់អន្តរ-ស្ថាប័ន (IILP) និងកម្មវិធីជំរុញពាណិជ្ជកម្ម និងវិនិយោគ (TIPP) បង្កើតឡើងដើម្បីអភិវឌ្ឍន៍ការផ្សារភ្ជាប់ពាណិជ្ជកម្មប្រកបដោយនិរន្តរភាព និងបង្កើនចំណេះដឹងនៃឱកាសសេដ្ឋកិច្ចដែលមានស្រាប់ក្នុងទីផ្សាររបស់ពួកគេរៀងៗខ្លួន។ ញ៉ូវហ្សេឡែន បានរួមចំណែកក្នុងមូលនិធិវិទ្យាសាស្ត្រអាស៊ាន ដោយផ្តោតសំខាន់លើការកសាងធនធានមនុស្ស ជាពិសេសកម្មវិធី

អាហារូបករណ៍សម្រាប់និស្សិតអាស៊ាន កម្មវិធីទស្សនកិច្ចសិក្សារបស់អ្នកការទូតវ័យក្មេងអាស៊ាន គំនិតផ្តួចផ្តើមថ្នាក់ដឹកនាំធុរកិច្ច និងការបណ្តុះបណ្តាលភាសាអង់គ្លេស ដែលចូលរួមចំណែកយ៉ាងសកម្មដល់ការពង្រឹងទំនាក់ទំនងអាស៊ាន-ញ៉ូហ្សីលែន ឲ្យកាន់តែរឹងមាំ និងយូរអង្វែង។

**អាស៊ាន-កាណាដា** គណៈកម្មាធិការសហប្រតិបត្តិការរួមអាស៊ាន-កាណាដា (ASEAN-Canada Joint Cooperation Committee - JCC) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨១ ពោលគឺ ៤ឆ្នាំបន្ទាប់ពីទំនាក់ទំនងកិច្ចសន្ទនាបានចាប់ផ្តើមពិតប្រាកដ។ គណៈកម្មាធិការអាស៊ាន-កាណាដា ត្រូវបានគាំទ្រដោយគណៈកម្មាធិការរួមផែនការ និងត្រួតពិនិត្យ។ ប្រទេសកាណាដាបាន និងកំពុងផ្តល់ជំនួយបច្ចេកទេសដល់គម្រោងអាស៊ានក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កសិកម្ម បរិស្ថាន ការអភិវឌ្ឍធនធានមនុស្ស វប្បធម៌ និងព័ត៌មាន និងស្ត្រីក្នុងការអភិវឌ្ឍ។ ប្រទេសកាណាដា ផ្តល់ការគាំទ្រដល់វិទ្យាស្ថានគ្រប់គ្រងព្រៃឈើអាស៊ាន ហើយក៏បានលើកទឹកចិត្តផងដែរ ដល់ការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជនក្នុងការអនុវត្តគម្រោងផ្សេងៗ ទន្ទឹមនឹងនោះ អនុគណៈកម្មការពាណិជ្ជកម្ម និងវិនិយោគរបស់JCCត្រូវបានបង្កើតឡើងផងដែរ។

**អាស៊ាន-ចិន** ប្រទេសចិនបានក្លាយជាដៃគូសន្ទនារបស់អាស៊ាន ចាប់តាំងពីឆ្នាំ១៩៩៦ បន្ទាប់ពីទំនាក់ទំនងពិគ្រោះយោបល់ដែលបានចាប់ផ្តើមឆ្នាំ១៩៩២។ ក្រោមគណៈកម្មាធិការសហប្រតិបត្តិការរួមអាស៊ាន-ចិន គឺជាគណៈកម្មាធិការរួម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងគណៈកម្មាធិការរួមវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ការពិគ្រោះយោបល់មន្ត្រីជាន់ខ្ពស់អាស៊ាន-ចិន ក៏ត្រូវបានបង្កើតឡើងផងដែរ ហើយត្រូវបានរៀបចំយ៉ាងទៀងទាត់ ក្រៅពីនេះប្រទេសចិន បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងជាសមាជិកស្ថាបនិកនៃវេទិកាតំបន់អាស៊ានផងដែរ។

កិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី២០ បានធ្វើឡើងនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ នៅក្នុងកិច្ចប្រជុំមេដឹកនាំនៃប្រទេសអាស៊ាន-ចិន បានគាំទ្រក្នុងការរៀបចំខួបលើកទី១៥ ស្តីពីភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន និងដាក់ចេញនូវចក្ខុវិស័យភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ឆ្នាំ២០៣០ នាកិច្ចប្រជុំកំពូលអាស៊ាន-ចិន ឆ្នាំ២០១៨ ហើយឆ្នាំ២០១៨ជាឆ្នាំនវានុវត្តភាពអាស៊ាន-ចិន។ ប្រទេសចិន ជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ានដែលមានទំហំពាណិជ្ជកម្មសរុប ៣៦៨ពាន់លានដុល្លារ ក្នុងឆ្នាំ២០១៦ ស្មើនឹង១៦,៥ភាគរយ នៃពាណិជ្ជកម្មទំនិញសរុបរបស់អាស៊ាន។ ឆ្នាំ២០១៧ ត្រូវបានកំណត់ថាជាឆ្នាំនៃកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងអាស៊ាន-ចិន ក្នុងគោលដៅបង្កើនភ្ញៀវទេសចរណ៍ទៅវិញទៅមក និងលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជនឲ្យកាន់តែប្រសើរឡើង ហើយអាស៊ានគាំទ្រចំពោះការបង្កើនកម្រិតនៃកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ទាំងនេះគឺក្នុងបំណងសម្រេចឲ្យបាននូវគោលដៅ ១ពាន់កោដិដុល្លារ (One Trillion USD) និងវិនិយោគ ១៥០ពាន់លានដុល្លារ នៅឆ្នាំ២០២០។ នៅក្នុងកិច្ចប្រជុំនេះដែរ មេដឹកនាំអាស៊ានបានឯកភាពលើកទឹកចិត្តឲ្យមានអ្នកជំនួញចិន មកធ្វើវិនិយោគ និងធុរកិច្ចបន្ថែមទៀតនៅអាស៊ាន ជាពិសេសនៅកម្ពុជា ក្នុងផ្នែកផលិតកម្មកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សហគ្រាសធុនតូច និងមធ្យម ថាមពល និងទេសចរណ៍ មិនតែប៉ុណ្ណោះមេដឹកនាំអាស៊ាន បានគាំទ្រសេចក្តីប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការទេសចរណ៍ និងកិច្ចសហប្រតិបត្តិការប្រឆាំងនឹងអំពើពុករលួយ។

នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៧ ឯកឧត្តមវ៉ាង យី បានលើកឡើងនៅ ៧ចំណុច ៖

១- បង្កើតចក្ខុវិស័យឆ្នាំ២០៣០ សម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ដែលជាផែនការលម្អិតសម្រាប់ការចង្អុលបង្ហាញនូវទំនាក់ទំនងនាពេលអនាគត

២- រួមបញ្ចូលគ្នានៅគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ វិថីមួយ ជាមួយនឹងផែនការមេរបស់សហគមន៍អាស៊ាន ឆ្នាំ២០២៥ និងបន្តពង្រីកវិសាលភាពសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី

៣- កំណត់ឆ្នាំ២០១៨ ជាឆ្នាំនៃនវានុវត្តន៍អាស៊ាន-ចិន

៤- ពន្លឿនការអនុវត្តលទ្ធផល ស្តីពីការធ្វើឲ្យប្រសើរឡើងនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងរួមគ្នាការពាររបបសេរីពាណិជ្ជកម្មជាសកល

៥- អនុវត្តឲ្យបានពេញលេញ និងមានប្រសិទ្ធភាពនៃសេចក្តីប្រកាសរួម ស្តីពីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតកម្មអាស៊ាន-ចិន និងជំរុញដំណើរការឧស្សាហកម្មភាវូបនីយកម្មទៅវិញទៅមក

៦- កសាងសសរស្តម្ភថ្មីសម្រាប់ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រជាជនសម្រាប់ការអបអរសាទរឆ្នាំ២០១៨ នៃកិច្ចសហប្រតិបត្តការទេសចរណ៍អាស៊ាន-ចិន និងស្នើចេញសេចក្តីប្រកាសរួមស្តីពី កិច្ចសហប្រតិបត្តិការទេសចរណ៍ ដើម្បីបញ្ចូលការគាំទ្រជាសាធារណៈ និងជាមូលដ្ឋានសង្គមសម្រាប់ទំនាក់ទំនងទ្វេភាគី

៧- ពន្លឿនការចរចា RCEP និងដឹកនាំដំណើរការនៃសមាហរណកម្មតំបន់រួមគ្នា។[7]

**អាស៊ាន-សហភាពអឺរ៉ុប** ទំនាក់ទំនងរបស់អាស៊ានជាមួយសហភាពអឺរ៉ុប (EU) បានចាប់ផ្តើមនៅឆ្នាំ១៩៧២។ ទំនាក់ទំនងនេះត្រូវបានធ្វើឡើងជាផ្លូវការនៅឆ្នាំ១៩៨០ តាមរយៈកិច្ចព្រមព្រៀងសហប្រតិបត្តិការអាស៊ាន-EC គណៈកម្មាធិការសហប្រតិបត្តិការរួមអាស៊ាន-EC ត្រូវបានបង្កើតឡើងដើម្បីជួយដល់កម្មវិធីរបស់អាស៊ាន ដើម្បីផ្សារភ្ជាប់ស្ថាប័ន បរិស្ថាន ការអភិវឌ្ឍ ធនធានមនុស្ស ការផ្លាស់ប្តូរវិទ្យាសាស្ត្រ និងបច្ចេកទេស និងការប្រឆាំងគ្រឿងញៀន។ គម្រោងនានាត្រូវបានអនុវត្តដើម្បីនាំមកនូវកិច្ចសហប្រតិបត្តិការឧស្សាហកម្មកាន់តែប្រសើរឡើង ការចូលរួមកាន់តែច្រើននៃស្ថាប័នហិរញ្ញវត្ថុរបស់សហភាពអឺរ៉ុប នៅក្នុង

[7] ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

គម្រោងអាស៊ាន និងការទទួលបានបច្ចេកវិទ្យាអាស៊ានកាន់តែច្រើន។ សហភាពអឺរ៉ុប បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់មជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវគ្រប់គ្រង ថាមពលអាស៊ាន-អឺរ៉ុប នៅទីក្រុងហ្សាកាតា មជ្ឈមណ្ឌលគ្រប់គ្រងអាស៊ាន-អឺរ៉ុបនៅទីក្រុងបង់ដាសេរីបេហ្គាវ៉ាន់ និងមជ្ឈមណ្ឌលASEAN Timber Technology (ATTC) នៅទីក្រុងកូឡាឡាំពួរ។ សហភាពអឺរ៉ុប គឺជាដៃគូសន្ទនារបស់អាស៊ាន ដែលរដ្ឋមន្ត្រីការបរទេសនៃភាគីទាំងពីរបានជួបប្រជុំគ្នា បន្ថែមពីសន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន។

**អាស៊ាន-សាធារណរដ្ឋកូរ៉េ** បានក្លាយជាដៃគូសន្ទនាពេញលេញមួយរបស់អាស៊ាន ក្នុងឆ្នាំ១៩៩១។ បច្ចុប្បន្ននេះ កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន បានគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វិទ្យាសាស្ត្រ និងបច្ចេកទេស សហប្រតិបត្តិការអភិវឌ្ឍន៍ និងការអភិវឌ្ឍធនធានមនុស្ស។ សាធារណរដ្ឋកូរ៉េ បានបង្កើតមូលនិធិសហប្រតិបត្តិការពិសេស (SCF) សម្រាប់គម្រោងអាស៊ាន-សាធារណរដ្ឋកូរ៉េ។ សកម្មភាពដំណើរការមួយចំនួន បានបញ្ចូលក្នុងគម្រោងស្រាវជ្រាវ ស្តីពីការបង្កើតប្រព័ន្ធអភិវឌ្ឍន៍ដំណើរការវិទ្យាសាស្ត្រ និងបច្ចេកទេស កម្មវិធីសហប្រតិបត្តិការអន្តរជាតិសម្រាប់ឧស្សាហូបនីយកម្មក្នុងអាស៊ាន និងកម្មវិធីផ្ទេរបច្ចេកទេស លើការអភិវឌ្ឍវិស័យកសិកម្ម។

អាស៊ាន-កូរ៉េ គឺជាដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដោយបានចេញសេចក្តីថ្លែងការរួម ស្តីពីភាពជាដៃគូយុទ្ធសាស្ត្រសម្រាប់សន្តិភាព និងភាពរុងរឿង រយៈពេលចាប់ពីឆ្នាំ២០១៦-២០២០ នាសន្និសីទថ្នាក់រដ្ឋមន្ត្រីកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥ ទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ រីឯកិច្ចព្រមព្រៀងលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន-កូរ៉េលើទំនិញ (ASEAN-Korea Trade in Good - AKTIG) ត្រូវបានអនុម័តនៅឆ្នាំ២០០៧ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-កូរ៉េលើសេវាកម្ម នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ហើយនៅក្រោមកិច្ចព្រមព្រៀងតំបន់សេរីអាស៊ាន-កូរ៉េ បានជំរុញឲ្យទំហំពាណិជ្ជកម្មនៃភាគីទាំងពីរ មានកំណើនរហូតដល់២០០ពាន់លានដុល្លារ នៅឆ្នាំ២០២០។ ម្យ៉ាងទៀត មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ ក៏ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ ដែលមជ្ឈមណ្ឌលនេះមានតួនាទីដ៏សំខាន់ក្នុងការជំរុញពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ កិច្ចសហប្រតិបត្តិការវប្បធម៌ និងទំនាក់ទំនង រវាងប្រជាជនអាស៊ាន និងប្រជាជនកូរ៉េផងដែរ។

**អាស៊ាន-សហព័ន្ធរុស្ស៊ី** បានក្លាយជាដៃគូសន្ទនាមួយរបស់អាស៊ានក្នុងឆ្នាំ១៩៩៦ បន្ទាប់ពីមានកិច្ចទំនាក់ទំនងលើកិច្ចពិគ្រោះយោបល់ ដែលបានចាប់ផ្ដើមក្នុងឆ្នាំ១៩៩២ គណៈកម្មាធិការសហប្រតិបត្តិការរួម បានបង្កើត និងរៀបចំកិច្ចប្រជុំដំបូងគេនៅក្នុងទីក្រុងម៉ូស្គូ កាលពីខែមិថុនា ឆ្នាំ១៩៩៧ ដូចជាបណ្ដាដៃគូសន្ទនាដទៃទៀតដែរ។ រីឯគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកទេសរួម ក៏បានបង្កើត និងរៀបចំកិច្ចប្រជុំនៅថ្ងៃដដែល នាទីក្រុងម៉ូស្គូផងដែរ។ តំបន់ដែលមានផលប្រយោជន៍រួម ដូចជា៖ កិច្ចសហប្រតិបត្តិការក្នុងជីវសាស្ត្រ ឧត្តុនិយមវិទ្យាសាស្ត្រ ភូគព្ភរូបវន្ត គ្រឿងអេឡិចត្រូនិកតូចៗ ព័ត៌មានវិទ្យា ឧបករណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយរុស្ស៊ី ជាសមាជិកស្ថាបនិកនៃវេទិកាតំបន់អាស៊ាន។

លទ្ធផលសំខាន់ៗចំនួនបីដែលទទួលបាននៅក្រោមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី រួមមាន៖

១- សេចក្តីប្រកាសរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី ស្តីពីកិច្ចប្រឹងប្រែងរួមដើម្បី ប្រយុទ្ធប្រឆាំងអំពើភេរវកម្មអន្តរជាតិ

២- ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តរបាយការណ៍ក្រុមឥស្សរជនឆ្នើមអាស៊ាន-រុស្ស៊ី

៣- ទស្សនទាន ស្តីពីការបង្កើតបណ្តាញក្រុមវិភាគភាពជាដៃគូអាស៊ាន-រុស្ស៊ី។

**អាស៊ាន-អាមេរិក** បានក្លាយជាដៃគូសន្ទនាមួយរបស់អាស៊ានក្នុងឆ្នាំ១៩៧៧។ ទំនាក់ទំនងនេះសង្កត់ធ្ងន់ក្នុងគោលដៅជំរុញការធ្វើពាណិជ្ជកម្ម និងវិនិយោគ ដែលដឹកនាំដោយវិស័យឯកជន តាមរយៈគម្រោងឱកាសពាណិជ្ជកម្ម និងវិនិយោគវិស័យឯកជនអាស៊ាន។ អ្នកតំណាងក្រុមប្រឹក្សាអាស៊ាន-អាមេរិក សម្រាប់ពាណិជ្ជកម្ម និងបច្ចេកវិទ្យា បានរួមចូលក្នុងកិច្ចសន្ទនារវាងភាគីទាំងពីរ។ អាមេរិក ក៏បានគាំទ្រលើកម្មវិធីកែលម្អបរិស្ថាន (EIP) ដែលមានគោលបំណងជំរុញការផ្ទេរបច្ចេកវិទ្យាអាមេរិក ដើម្បីធ្វើឲ្យប្រសើរឡើងនូវសេដ្ឋកិច្ច និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ ដោយឧស្សាហកម្មក្នុង

ស្រុករបស់អាស៊ាន។ ជាមួយនឹងការគាំទ្ររបស់អាមេរិក មជ្ឈមណ្ឌលព័ត៌មានគ្រប់គ្រងបរិស្ថាន និងបច្ចេកវិទ្យាស្អាត ត្រូវបានបង្កើតឡើងក្នុងទីក្រុងហ្សាកាតា ម៉ានីល និងទីក្រុងសឹង្ហបុរី ដើម្បីលើកទឹកចិត្តដល់ឧស្សាហកម្មអាស៊ាន ក្នុងការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានដែលមានភាពងាយស្រួល។ ក្រុមប្រឹក្សាស្របច្បាប់ ក៏បានរៀបចំកិច្ចប្រជុំរវាងថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងតំណាងពាណិជ្ជកម្មអាមេរិក។

**អាស៊ាន-ឥណ្ឌា** បានព្រមព្រៀងគ្នាក្នុងឋានៈជាដៃគូសន្ទនាក្នុងអាស៊ាន ចាប់ពីឆ្នាំ១៩៩៥។ ឥណ្ឌា ចាប់ផ្ដើមធ្វើជាដៃគូតាមវិស័យរបស់អាស៊ាន តាំងពីដើមឆ្នាំ១៩៩៣។ គណៈកម្មាធិការសហប្រតិបត្តិការរួមគ្នាអាស៊ាន-ឥណ្ឌា បានបង្កើតក្រុមការងារ២ ដោយមួយផ្ដោតលើវិទ្យាសាស្ត្រ និងបច្ចេកទេស និងមួយទៀតផ្ដោតលើវិស័យពាណិជ្ជកម្ម និងកិច្ចការវិនិយោគ។ កិច្ចសហប្រតិបត្តិការនេះ បាន និងកំពុងស្វែងយល់លើវិស័យទេសចរណ៍ អភិវឌ្ឍន៍ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលដល់ការទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ ទន្ទឹមនឹងនោះក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា និងគណៈកម្មាធិការគ្រប់គ្រងរួមសម្រាប់មូលនិធិអាស៊ាន-ឥណ្ឌា ក៏ត្រូវបានបង្កើតឡើងផងដែរ។



**អាស៊ាន-UNDP** កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) គឺជាអង្គការពហុភាគីតែមួយគត់ ដែលត្រូវបានព្រមព្រៀងគ្នាក្នុងឋានៈជាដៃគូសន្ទនា ក្នុងអាស៊ាន។ UNDP បានកំពុងផ្តល់នូវជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ក្នុងគម្រោងអាស៊ាន ចាប់តាំងពីឆ្នាំ១៩៧៧។ គម្រោងជំនួយUNDP ដែលសំខាន់ៗសម្រាប់ ០២ នៃអាស៊ាន រួមមានជំនួយបច្ចេកទេសលើ (ក) ការកែលម្អរចនាសម្ព័ន្ធ និងការពង្រឹងលេខាធិការដ្ឋានអាស៊ាន និង(ខ) ការបង្កើតកម្មវិធី និងប្រព័ន្ធគ្រប់គ្រងគម្រោងនៅលេខាធិការដ្ឋានអាស៊ាន។ កម្មវិធីអនុតំបន់អាស៊ាន (ASP) ដែលមានសមាសធាតុបន្តបន្ទាប់ដូចជា (ក) អភិវឌ្ឍន៍ធនធានមនុស្ស (ខ) ការកសាងសមត្ថភាព (គ) សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគ (ឃ) ពាណិជ្ជកម្ម និងបរិស្ថាន (ង) វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ច) បណ្តាញអាស៊ានសម្រាប់ស្ត្រីក្នុងការបណ្តុះបណ្តាលជំនាញ និង (ឆ) កិច្ចសហប្រតិបត្តិការអនុតំបន់រវាងអាស៊ាន និងកម្ពុជា ឡាវ និងវៀតណាម។

**អាស៊ាន-តួកគី** បានក្លាយជាដៃគូសន្ទនាតាមវិស័យរបស់អាស៊ាន (sectorial dialogue partners) ដែលបានអនុម័តក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី៥0 ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

**អាស៊ាន-ជប៉ុន** លើកិច្ចទំនាក់ទំនងសន្ទនារវាងភាគីទាំងពីរ ត្រូវបានបង្កើតក្នុងឆ្នាំ១៩៧៧ ទោះបីជាមានទំនាក់ទំនងតាំងពីឆ្នាំ១៩៧៣ ដែលជាទំនាក់ទំនងក្រៅផ្លូវការ។ អាស៊ាន និងជប៉ុន បានធ្វើសហប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម ទំនិញ វិនិយោគ ការផ្លាស់ប្តូរជំនួយបច្ចេកទេស និងអភិវឌ្ឍន៍។ មជ្ឈមណ្ឌលជំរុញវិស័យពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍អាស៊ាន ត្រូវបានបង្កើតឡើងក្នុងទីក្រុងតូក្យូ ក្នុងគោលដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការវិស័យឯកជន។ ជប៉ុន ក៏បានពង្រីកការគាំទ្រផ្នែកហិរញ្ញវត្ថុលើការអនុវត្តដូចជា ការបង្កើតមូលនិធិវប្បធម៌អាស៊ាន (ACF) កម្មវិធីផ្លាស់ប្តូរចំណេះដឹងជប៉ុន-អាស៊ាន (JAEP) មូលធិនិអាហារូបករជប៉ុនសម្រាប់យុវជនអាស៊ាន កម្មវិធីផ្លាស់ប្តូរបច្ចេកទេសអន្តរអាស៊ាន

(IATEP) និងគម្រោង អភិវឌ្ឍន៍ធនធានមនុស្ស។ ម្យ៉ាងទៀត ជប៉ុនក៏បាននឹងកំពុងរួមចំណែកក្នុងការប្រឹងប្រែងដើម្បីអភិវឌ្ឍន៍អាងទន្លេមេគង្គផងដែរ។[8] នៅក្នុងកិច្ចប្រជុំកំពូលមេគង្គជប៉ុនលើកទី៩ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ថ្នាក់ដឹកនាំនៃបណ្តាទន្លេមេគង្គបានសម្រេចៈ

- ទទួលស្គាល់លទ្ធផលសំខាន់ៗ ដែលសម្រេចបាន ដើម្បីសម្រេចយុទ្ធសាស្ត្រក្រុងតូក្យូ ឆ្នាំ២០១៥
- រយៈពេល២ឆ្នាំ បន្ទាប់ពីការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រក្រុងតូក្យូ ឆ្នាំ២០១៥ និងចក្ខុវិស័យការអភិវឌ្ឍឧស្សាហកម្មមេគង្គជប៉ុន បានឧបត្ថម្ភជាង២ភាគ៣ នៃជំនួយសរុប ៧៥០ពាន់លានយ៉េន (ប្រមាណ៦.៦ពាន់លានដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៦-២០១៨។ ទន្ទឹមនឹងនេះដែរ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសមេគង្គទាំងអស់មានការកោតសរសើរចំពោះការប្តេជ្ញារបស់ប្រទេសជប៉ុន ក្នុងការប្តេជ្ញារបស់ប្រទេសជប៉ុន ក្នុងការដាក់ចេញភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តភាព និងការអនុវត្តដំណើការនៃគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍធនធានមនុស្សផ្នែកឧស្សាហកម្ម។ រីឯកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុនលើកទី១០ នឹងប្រព្រឹត្តទៅនៅប្រទេសជប៉ុន ឆ្នាំ២០១៨ និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១១ នៅប្រទេសសឹង្ហបុរី ឆ្នាំ២០១៨។

ជប៉ុនជាដៃគូសន្ទនារបស់អាស៊ាន និងជាសមាជិកភាពក្នុងអង្គការតំបន់សំខាន់ៗជាច្រើន ដូចជាៈ សមាជិកមិនអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (Non-Permanent member of UN Security Council) អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) អង្គការសហប្រតិបត្តិការអាស៊ីប៉ាស៊ីហ្វិក (APEC) កិច្ចប្រជុំG-៧ កិច្ចប្រជុំG-២០ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអន្តរប៉ាស៊ីហ្វិក (Trans-Pacific Partnership-TPP)។[9]

---

[8] ទំនាក់ទំនងដៃគូក្រៅតំបន់

[9] ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

អាស៊ាន-ជប៉ុន បានសម្រេចការសម្រួលផែនការអនុវត្តសេចក្តីប្រកាសចក្ខុវិស័យស្តីពី មិត្តភាព និងសហប្រតិបត្តិការអាស៊ាន-ជប៉ុន ដោយរួមបញ្ចូលការអភិវឌ្ឍថ្មីៗជាច្រើន និងការបន្សុីគ្នាទៅតាមវិស័យ អាទិភាពថ្មីៗរបស់អាស៊ាន ហើយជប៉ុនបានស្នើបង្កើតកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការបច្ចេកទេស រវាងជប៉ុន និងអាស៊ាន ដោយបន្ថែមលើមូលនិធិជប៉ុនសម្រាប់សមាហរណកម្មអាស៊ាន (Japan-ASEAN Integration Fund-JAIF) ដើម្បីអាចផ្តល់លទ្ធភាពដល់ JICA អនុវត្តគម្រោងដែលស្នើដល់ប្រទេស សមាជិកអាស៊ានដោយផ្ទាល់ ក្នុងការប្រើប្រាស់នូវគុណភាពនៃជំនាញខ្ពស់។ ភាគីទាំងពីរកំពុងបន្ត ពិភាក្សាលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ។ ម្យ៉ាងទៀត ជប៉ុនបានបន្តផ្តល់ការគាំទ្រយ៉ាងមុតមាំក្នុងការ កសាងធនធានមនុស្សសម្រាប់អាស៊ាន ជាពិសេសដល់មន្ត្រីមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម ដើម្បីចូលរួមវគ្គកម្មសិក្សា នៅលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាកាតា។




ជប៉ុន គឺជាដៃគូពាណិជ្ជកម្មធំទីបី បន្ទាប់ពីចិន និងសហគមន៍អឺរ៉ុប ហើយក៏ជាប្រភពទុនវិនិយោគធំ លំដាប់ទីពីររបស់អាស៊ានផងដែរ។ នៅក្នុងឆ្នាំ២០១៧ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងអាស៊ាន-ជប៉ុន មាន ចំនួន ២០៨.៧៧ ពាន់លានដុល្លារសហរដ្ឋអាមេរិក មានការកើនឡើងចំនួន ៩.៩៥% បើធៀបនឹង

ឆ្នាំ២០១៦ ដែលស្មើនឹង ៧.៩៤% នៃទំហំពាណិជ្ជកម្មសរុបរបស់អាស៊ាន។ ដើម្បីស្របតាមការអភិវឌ្ឍឧស្សាហកម្ម និងការអនុវត្តអាជីវកម្មបច្ចុប្បន្ននោះ ជប៉ុន-អាស៊ាននឹងបន្តកិច្ចខិតខំប្រឹងប្រែងបង្កើនពាណិជ្ជកម្មទ្វេដងទៀត នៅឆ្នាំ២០២២ខាងមុខ។

ប្រទេសជប៉ុន ស្វាគមន៍ចំពោះវឌ្ឍនភាពរវាងអាស៊ាន-ជប៉ុននៅក្នុងការអនុវត្តនៃផែនទីបង្ហាញផ្លូវលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាយុទ្ធសាស្ត្រ ១០ឆ្នាំ ក្នុងវិស័យផ្សេងៗ រួមទាំងសកម្មភាពលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម (MSMEs) ហេដ្ឋារចនាសម្ព័ន្ធ ការច្នៃប្រឌិតថ្មី និងការផ្ទេរបច្ចេកវិទ្យា ដោយកត់សម្គាល់ថាផែនទីបង្ហាញផ្លូវនេះនឹងលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចរបស់អាស៊ាននៅក្នុងវិស័យផ្សេងៗ ដូចជាកម្មសិទ្ធិបញ្ញាស្តង់ដារគយ និងការផ្តួចផ្តើមនូវការសម្របសម្រួលពាណិជ្ជកម្មរវាងគ្នាទៅវិញទៅមក និងបានព្រមព្រៀងគ្នាលើអត្ថប្រយោជន៍ នៃគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ធនធានមនុស្ស ខាងផ្នែកឧស្សាហកម្ម ក្នុងការកសាងសមត្ថភាពកាន់តែខ្ពស់សម្រាប់អាជីវកម្មរវាងជប៉ុន-អាស៊ាន។ ម្យ៉ាងទៀតជប៉ុនបានទទួលស្គាល់ថាគំនិតផ្តួចផ្តើមនានា ដូចជាមូលនិធិអាស៊ាន-ជប៉ុនផ្តល់សិទ្ធិឲ្យស្ត្រី បានលើកទឹកចិត្តដល់សហគ្រិនជាស្ត្រី ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍស្ត្រីក្នុងសង្គម ការបង្កើតការងារដែលជាការជំរុញដល់កំណើនសេដ្ឋកិច្ចផងដែរ។

បណ្តាញនៃការច្នៃប្រឌិតអាស៊ាន-ជប៉ុន (AJIN) ដែលត្រូវបានផ្តួចផ្តើមគំនិតដោយវិស័យឯកជនលើការងារជំរុញការច្នៃប្រឌិតថ្មីទូទាំងវិស័យ និងឧស្សាហកម្ម ដោយរួមបញ្ចូលទាំងទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថលសម្រាប់MSMEs និងឧស្សាហកម្មកំពុងរីកចម្រើន គឺជាការរួមចំណែកនៃការបង្ហាញផ្លូវឆ្ពោះទៅរកការពង្រឹងកិច្ចសហប្រតិបត្តិការខាងវិស័យសេដ្ឋកិច្ច និងឧស្សាហកម្ម ស្របតាមការអនុវត្តនូវផែនទីបង្ហាញផ្លូវសេដ្ឋកិច្ចជាយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំរវាងអាស៊ាន-ជប៉ុន។ ជាមួយនឹងការអនុវត្ត

ដ៏ជោគជ័យនៃផែនទីបង្ហាញផ្លូវខាងលើនេះ គឺបានបន្តការគាំទ្រដល់ដំណើរការដែលជាគំនិតផ្តួចផ្តើមនៃការធ្វើសមារណកម្មសេដ្ឋកិច្ចអាស៊ាន ពិសេសការជំរុញសហប្រតិបត្តិការ និងបរិយាកាសច្នៃប្រឌិតថ្មី ដោយផ្តល់នូវបច្ចេកទេសផ្សេងៗ និងការបង្កើនសមត្ថភាពសម្រាប់ MSMEs របស់អាស៊ាន-ជប៉ុន ការជំរុញវប្បធម៌នៃការច្នៃប្រឌិតថ្មី កិច្ចសម្រួលពាណិជ្ជកម្មតាមអេឡិចត្រូនិច និងការបង្កើតគោល-នយោបាយ ការអភិវឌ្ឍឧស្សាហកម្មថ្មី និងជំរុញការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការផ្តួចផ្តើមគំនិតដើម្បីជួយ MSMEs របស់អាស៊ាន ក្នុងការតភ្ជាប់ជាមួយនឹងខ្សែសង្វាក់តម្លៃពិភពលោក ក្នុងភាពជាដៃគូពាណិជ្ជកម្មយូរអង្វែង។

សារៈសំខាន់នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន-ជប៉ុន (AJCEP) បានរួមចំណែកដល់ការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ និងវិបុលភាពនៃការទាញយកអត្ថប្រយោជន៍នៃកំណើនឡើងពាណិជ្ជកម្ម និងវិនិយោគ។ អាស៊ាន-ជប៉ុន បានបញ្ចប់ពិធីសារកែតម្រូវកិច្ចព្រមព្រៀង AJCEP ដើម្បីបញ្ចូលក្នុងជំពូកស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្ម Movement of Natural Persons និងវិនិយោគ ដោយសង្ឃឹមថានឹងចុះហត្ថលេខានៅដើមឆ្នាំ២០១៨នេះ។

ម្យ៉ាងវិញទៀត មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន បានដើរតួនាទីយ៉ាងសំខាន់ដើម្បីជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ព្រមទាំងចំណេះដឹងវប្បធម៌ រវាងជប៉ុន និងអាស៊ាន។ ជាមួយគ្នានេះ មជ្ឈមណ្ឌលបាននិងកំពុងលើកកម្ពស់ និងជំរុញការនាំចេញពីអាស៊ាន ទៅជប៉ុន ស្របគ្នានឹងការជំរុញការវិនិយោគ និងទេសចរណ៍ពីជប៉ុន មកកាន់អាស៊ាន តាមរយៈការរៀបចំពិព័រណ៍ផលិតផលអាស៊ាន សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល និងការអញ្ជើញបេសកកម្ម ការចងក្រងផ្សព្វផ្សាយ និងសេវាផ្តល់ព័ត៌មាន ។ល។

ក្រៅពីដៃគូសន្ទនារបស់ខ្លួន អាស៊ានក៏បានរក្សានូវទំនាក់ទំនងជាមួយបណ្ដាអង្គការអន្តរជាតិ និងក្រុមការងារក្នុងតំបន់ជាច្រើនទៀត រួមមាន វេទិកាប៉ាស៊ីហ្វិកខាងត្បូង អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការឈូងសមុទ្រ ក្រុមការងារRIO សមាគមអាស៊ីខាងត្បូងសម្រាប់កិច្ច-សហការតំបន់ និងសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង។ ក្រុមប្រឹក្សាក៏បានរៀបចំក្រុមការងារសេដ្ឋកិច្ចតំណាងប្រទេស ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធអាស៊ាន-ញូវហ្សឺឡែនសមាគមពាណិជ្ជកម្មសេរីអឺរ៉ុប ទីផ្សារមុំរួមភាគខាងត្បូង និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង។

ទំនាក់ទំនងសន្ទនារបស់អាស៊ានជាមួយប្រទេសទី៣ និងអង្គការក្នុងតំបន់ និងអន្តរជាតិនានាទទួលបានផ្លែផ្កាកាន់តែខ្លាំងឡើង។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ បានពង្រីកដៃគូសន្ទនា ហើយអាស៊ានក៏បានពង្រីកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ខ្លួន ដោយខិតខំប្រឹងប្រែង និងធានាការចូលទៅកាន់ទីផ្សារបរទេស បច្ចេកវិទ្យា និងមូលធនជាដើម។ បន្ថែមពីនេះ អាស៊ានក៏បានបង្ហាញអំពីទិដ្ឋភាព និងតួនាទីរបស់ខ្លួនលើបញ្ហាសកល និងតំបន់ ជាមួយផលប៉ះពាល់គួរឲ្យកត់សម្គាល់ និងធានាបាននូវការគាំទ្រពីបណ្ដាប្រទេសសំខាន់ៗ លើតួនាទីរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានានា។[10]

ទន្ទឹមនឹងនេះដែរ ដើម្បីលើកកម្ពស់ និងបំពេញបន្ថែមនូវទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងរបៀបវារៈអ.ស.ប ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានគាំទ្រឲ្យមានជំនួបជាទៀងទាត់រវាងលេខាធិការដ្ឋានទាំង២ ចំនួន២ដង/១ឆ្នាំ គឺនៅលេខាធិការដ្ឋានទីក្រុងហ្សាកាតា និងទីស្នាក់ការអ.ស.ប ទីក្រុងញូវយក។

---

[10] ទំនាក់ទំនងដៃគូក្រៅតំបន់

## ចំណែកនៃពាណិជ្ជកម្មសរុបរបស់អាស៊ាននៅលើទំនិញ ជាមួយដៃគូសន្ទនា




ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧

## ការនាំចេញទំនិញ ជាមួយដៃគូសន្ទនា




ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧

## ការនាំចូលទំនិញ ជាមួយដៃគូសន្ទនា




ប្រភព៖ គំនូសតាងAEC ឆ្នាំ២០១៧

## ៨. ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន

### ៨.១. ទំនាក់ទំនងការទូត

ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន បានបង្កើតទំនាក់ទំនងការទូតជាផ្លូវការនៅថ្ងៃទី0៩ ខែមករា ឆ្នាំ១៩៥៣ និងក្រោយមកបានព្រមព្រៀងចុះសន្ធិសញ្ញាមិត្តភាពកម្ពុជា-ជប៉ុន នៅថ្ងៃទី0៩ ខែធ្នូ ឆ្នាំ១៩៥៥។ រហូតមកដល់ឆ្នាំ១៩៩២ ជប៉ុនបានបើកស្ថានទូតប្រចាំនៅរាជធានីភ្នំពេញឡើងវិញ និងនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៤ កម្ពុជាក៏បានបើកស្ថានទូតឡើងវិញប្រចាំនៅរដ្ឋធានីតូក្យូ។ កាលពីឆ្នាំ ២០១៣ ប្រទេសទាំងពីរ បានរៀបចំកម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦0 នៃការបង្កើតទំនាក់ទំនងការទូត កម្ពុជា-ជប៉ុន និងបានដំឡើងទំនាក់ទំនងនេះ ទៅជា "**ដៃគូយុទ្ធសាស្ត្រ**" ក្នុងគោលបំណងរីតចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។




## ខួបអនុស្សាវរីយ៍ លើកទី៦៥ នៃទំនាក់ទំនងការទូត រវាង ជប៉ុន និង កម្ពុជា

បន្ថែមពីនេះ កម្ពុជា-ជប៉ុន បានបង្កើតទំនាក់ទំនងនីតិបញ្ញត្តិ គឺនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ បានបង្កើតទំនាក់ទំនងមិត្តភាពទ្វេភាគីរដ្ឋសភាកម្ពុជា-ជប៉ុន និងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ បានបង្កើតទំនាក់ទំនងមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា និងព្រឹទ្ធសភាជប៉ុនផងដែរ។ ជាមួយគ្នានេះ កម្ពុជា-ជប៉ុន មានការផ្លាស់ប្តូរទស្សនកិច្ច រវាងថ្នាក់ដឹកនាំទាំងពីរ ដោយទទួលបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈជាច្រើន ដោយក្នុងនោះរួមមានទស្សនកិច្ចផ្លូវរដ្ឋ ទស្សនកិច្ចផ្លូវការ ការចូលរួមកិច្ចប្រជុំពិសេស និងកិច្ចប្រជុំនានា។[11]

### ៨.២. ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ជប៉ុន

នៅក្នុងឆ្នាំ២០១៧ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-ជប៉ុន មានចំនួន ១,៦២០.៩៧លានដុល្លារសហរដ្ឋអាមេរិក ដែលមានការកើនឡើងចំនួន ៦.៧៩% បើធៀបនឹងឆ្នាំ២០១៦ ហើយកម្ពុជាមានអតិរេកពាណិជ្ជកម្មក្នុងឆ្នាំ២០១៧ ជាមួយនឹងប្រទេសជប៉ុនចំនួន ៩០៤.៨៣ លានដុល្លារសហរដ្ឋអាមេរិក។

[11] ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ




## ៨.៣. ការវិនិយោគជប៉ុន នៅកម្ពុជា

គិតត្រឹមឆ្នាំ២០១៧ ក្រុមហ៊ុនជប៉ុនដែលវិនិយោគនៅកម្ពុជាមានចំនួន ២៤២ក្រុមហ៊ុន ស្មើនឹង ១៣០គម្រោង ដែលមានទុនវិនិយោគប្រមាណជាង១.៦ប៊ីលានដុល្លារសហរដ្ឋអាមេរិក និងបានបង្កើតការងារប្រមាណជា ៣៦,០០០កន្លែង។

**ចំណាត់ថ្នាក់លំហូរទុនវិនិយោគជប៉ុនមកកម្ពុជា ក្នុងរយៈពេល ៤ឆ្នាំ (២០១៤-២០១៧)**

| ឆ្នាំ | ចំនួនទុនវិនិយោគជប៉ុន *(លានដុល្លារអាមេរិក)* | ភាគរយ (%) | ចំណាត់ថ្នាក់ |
|---|---:|---:|---:|
| ២០១៧ | ៦៣.៤៧ | ១.០០ | ៧ |
| ២០១៦ | ៨២២.៤១ | ២២.៧៨ | ៣ |
| ២០១៥ | ៥៩.៥៨ | ១.២៨ | ៧ |
| ២០១៤ | ៦៧.៦២ | ១.៧២ | ៣ |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ជារួមគម្រោងវិនិយោគជប៉ុនទាំងតូចទាំងធំនៅកម្ពុជាបច្ចុប្បន្នមានចំនួនប្រមាណជាង ១ពាន់ ដែលសកម្មភាពក្នុងវិស័យផ្សេងៗ ដូចជា ធនាគារ ឧស្សាហកម្ម សេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធ ។ល។[12]

## ៨.៤. ចំនួនភ្ញៀវទេសចរណ៍ជប៉ុន មកទស្សនាកម្ពុជា

| ឆ្នាំ | ចំនួនភ្ញៀវសរុប | ចំនួនភ្ញៀវជប៉ុន | ភាគរយ (%) | ចំណាត់ថ្នាក់ |
|---|---|---|---|---|
| ២០១៧ | ៥.៦០លាននាក់ | ២០៣,៣៧៣នាក់ | ៣.៦ | ៧ |
| ២០១៦ | ៥.០១លាននាក់ | ១៩១,៥៧៧នាក់ | ៣.៨ | ៧ |
| ២០១៥ | ៤.៧៨លាននាក់ | ១៩៣,៣៣០នាក់ | ៤.០ | ៧ |
| ២០១៤ | ៤.៥០លាននាក់ | ២១៥,៧៨៨នាក់ | ៤.៨ | ៦ |

ប្រភព៖ ក្រសួងទេសចរណ៍, ព្រះរាជាណាចក្រកម្ពុជា

[12] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

កាលពីឆ្នាំ២០១៦ ភ្ញៀវទេសចរណ៍ជប៉ុនមកកាន់កម្ពុជា មានចំនួន ១៩១,៥៧៧នាក់ និងនៅឆ្នាំ២០១៧ មាន ២០៣,៣៧៣នាក់ មានការកើនឡើង ៦.00ភាគរយធៀបនឹងឆ្នាំ២០១៦កន្លងទៅ។[13] ទាំងនេះដោយសារតែមានការហោះហើរត្រង់ និងទៀងទាត់ មួយដង ក្នុងមួយថ្ងៃរបស់ក្រុមហ៊ុនជប៉ុន All Nippon Airways (ANA) ពីអាកាសយានដ្ឋានអន្តរជាតិណារីតា ទីក្រុងតូក្យូ មកកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ដោយប្រើយន្តហោះប្រភេទ Boeing 787។

ក្នុងកំឡុងឆ្នាំ២០០៧ មកទល់នឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ កម្ពុជាមានសិក្ខាកាមជំនាញបច្ចេកទេសនៅជប៉ុនចំនួន៥៩៣១នាក់ ក្នុងនោះស្រី៣៤២២នាក់ ហើយក្នុងរយៈពេល១១ខែ ឆ្នាំ២០១៧ កម្ពុជាបានបញ្ជូននិស្សិតចំនួន២០៣៤នាក់ ក្នុងនោះមានស្រីចំនួន១០៩១នាក់។ ម្យ៉ាងវិញទៀតកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈកម្ពុជា ជាមួយនឹងក្រសួងយុត្តិធម៌ ក្រសួងការបរទេស និងក្រសួងសុខាភិបាលការងារ និងសុខុមាលភាពជប៉ុន បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចសហប្រតិបត្តិការលើកម្មវិធីបណ្តុះបណ្តាលកម្មសិក្ខាការីជំនាញបច្ចេកទេស។ រីឯជំនួយរបស់ជប៉ុនចំពោះកម្ពុជាវិញ មានហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន។ ទន្ទឹមនឹងដែរ ជប៉ុនក៏បាន ផ្តល់ជាជំនួយសម្រាប់សាលាក្តីខ្មែរក្រហម កិច្ចសហប្រតិបត្តិការនយោបាយ និងយោធា និងជំនួយសម្រាប់គ្រោះធម្មជាតិជាដើម។

## ៩. ការចូលរួមរបស់កម្ពុជានៅក្នុងសហគមន៍អាស៊ាន និងទំនាក់ទំនងជាមួយដៃគូ

ដើម្បីសម្រេចបាននូវគោលការណ៍របស់អាស៊ាន ជាសហគមន៍មួយដែលផ្អែកលើវិធានការដោយយកប្រជាជនជាធំ ជាពិសេសលើការអនុវត្តទស្សនវិស័យរបស់សហគមន៍អាស៊ានឆ្នាំ២០២៥ និងមាគ៌ាឆ្ពោះទៅមុខ កម្ពុជាតែងចូលរួមយ៉ាងសកម្មជាមួយសមាជិកអាស៊ានទាំងអស់ ដោយការចូលរួមផ្លាស់ប្តូរមតិយោបល់ជាយុទ្ធសាស្ត្រ ការផ្តល់គំនិតផ្តួចផ្តើមនានា ព្រមទាំងចូលរួមអនុវត្តលើសេចក្តីសម្រេចទាំងឡាយរបស់អាស៊ាន និងចូលរួមរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានជាមួយដៃគូអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធដទៃទៀត។ មិនតែប៉ុណ្ណោះនៅក្នុងដំណើរការកសាងសហគមន៍

[13] ក្រសួងទេសចរណ៍, ព្រះរាជាណាចក្រកម្ពុជា

អាស៊ានក្នុងឋានៈជាប្រទេសសមាជិកដ៏សកម្មមួយ កម្ពុជាបានចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមជាសកលដោយឈរលើគោលការណ៍គ្រឹះរបស់អាស៊ាន នៃការមិនជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់គ្នា ពោលគឺ កម្ពុជាពង្រឹងយន្តការសម្របសម្រួលអាស៊ាន និងការពិគ្រោះយោបល់ និងធ្វើសេចក្តីសម្រេចដោយកុងសង់ស៊ីស (Consensus) ទាំងនេះគឺដើម្បីគោលដៅរក្សាអាស៊ាន ជាតំបន់មានសន្តិភាព ស្ថិរភាពយូរអង្វែង កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព វិបុលភាព និងវឌ្ឍនភាពសង្គម។

នៅក្នុងទំនាក់ទំនងរបស់អាស៊ានជាមួយដៃគូ កម្ពុជាតែងខិតខំបន្តជំរុញ និងលើកកម្ពស់នូវរាល់ទំនាក់ទំនងភាពជាដៃគូរបស់អាស៊ាន និងការរក្សាតួនាទីស្នូលរបស់អាស៊ាន ក្នុងគំនិតផ្តួចផ្តើមនានាស្តីពីនិម្មាបនកម្មតំបន់តាមរយៈយន្តការនាំមុខដោយអាស៊ាន ដែលកម្ពុជាឈរលើជំហរ អព្យាក្រឹត្យ និងភាពជាដៃគូក្នុងផលប្រយោជន៍ទៅវិញទៅមកនៃទំនាក់ទំនងរួម និងសម្លឹងឆ្ពោះទៅខាងក្រៅដែលមិនធ្វើឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់។



ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យកម្ពុជាក្លាយជាសមាជិកស្មើភាព និងស្មើសិទ្ធិនៃប្រជាជាតិអាស៊ីអាគ្នេយ៍ និងប្រទេសដ៏ទៃទៀតនៅគ្រប់វេទិកាតំបន់ និងពិភពលោក នេះជាមោទនភាព និងសេចក្ដីថ្លៃថ្នូរដ៏ធំធេងរបស់ជាតិយើង។ នៅក្នុងបរិបទនេះ កម្ពុជាបានរួមចំណែកដល់ការបង្កើនទំនាក់ទំនងរវាងអាស៊ាន ជាមួយដៃគូខាងក្រៅ ដែលបានជួយពង្រឹងដល់មជ្ឈភាពរបស់អាស៊ាន និងរក្សានៅក្នុងកៅអីអ្នកកាន់ចង្កូតនៃនិម្មាបនកម្មតំបន់។

ម្យ៉ាងវិញទៀត អត្ថប្រយោជន៍ដែលកម្ពុជាទទួលបាននៅក្នុងអាស៊ាននោះគឺ សិទ្ធិស្មើគ្នារបស់កម្ពុជានៅក្នុងការបញ្ចេញទស្សនៈ និងផ្លាស់ប្ដូរយោបល់ខាងផ្នែកនយោបាយ ដោយមិនប្រកាន់ថាប្រទេសធំ ឬតូច មាន ឬក្រ និងបានធ្វើឲ្យកម្ពុជាជៀសផុតពីការជ្រៀតជ្រែកពីប្រទេសដ៏ទៃនៅក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន មិនតែប៉ុណ្ណោះកម្ពុជាពង្រឹងបាននូវទំនាក់ទំនងការទូតជាមួយ សមាជិកអាស៊ានដូចគ្នា និងដៃគូសន្ទនារបស់អាស៊ាន ជាពិសេស ការទទួលស្គាល់នូវតួនាទីដ៏សំខាន់ និងមានកិត្យានុភាពរបស់កម្ពុជានៅក្នុងតំបន់ និងឆាកអន្តរជាតិ។ ទន្ទឹមនិងនេះដែរ នៅក្នុងផ្នែកសេដ្ឋកិច្ចកម្ពុជា ទទួលបាននូវការទាក់ទាញវិនិយោគ និងបង្កើនទំនុកចិត្តពីបណ្ដាប្រទេសនៅក្នុងតំបន់ និងដៃគូរបស់អាស៊ាន ហើយតាមរយៈគម្រោងអភិវឌ្ឍន៍នានា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការអាស៊ាន កិច្ចសហប្រតិបត្តិការអាស៊ានបូកបី អាស៊ានបូកប្រាំមួយ និងកិច្ចសហប្រតិបត្តិការដៃគូសន្ទនាអាស៊ាន គឺកម្ពុជាទទួលបានជំនួយឧបត្ថម្ភ ឬការគាំទ្រផ្សេងៗ ព្រមជាមួយនឹងផលចំណេញពីគម្រោងនៃគំនិតផ្ដួចផ្ដើមសម្រាប់សមាហរណកម្មអាស៊ាន ដែលផ្ដោតលើការកាត់បន្ថយគម្លាតអភិវឌ្ឍន៍នៅក្នុងប្រទេសសមាជិកអាស៊ាន និងការទទួលបានផលចំណេញទាំងស្រុងពីគម្រោងស្ថាបនាផ្លូវដែកតភ្ជាប់ពីសឹង្ហបុរី ទៅទីក្រុងគុនមីញ (ប្រទេសចិន) ចំពោះការស្ថាបនាផ្លូវខ្វះចន្លោះក្នុងប្រទេសកម្ពុជា រួមជាមួយកំណើនទេសចរណ៍ផងដែរ។[14]

---

[14] ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ១០. សន្និដ្ឋាន

ជាការពិតណាស់ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងជាង ៥០ឆ្នាំកន្លងមកហើយ និងមានវឌ្ឍនភាពគួរឲ្យចាប់អារម្មណ៍ ពិសេសដំណើរឆ្ពោះមកសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ AEC បានធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់គួរកត់សម្គាល់ ជាពិសេស ការលុបបំបាត់ពន្ធគយលើពាណិជ្ជកម្មអន្តរ-អាស៊ាន និងការកសាងមូលដ្ឋានគ្រឹះសម្រាប់សមាហរណកម្មសេដ្ឋកិច្ច តាមរយៈវិធានការទាក់ទងនឹងការវិនិយោគ គយ សុខដុមនីយកម្មនៃទំនិញក្នុងតារាងពន្ធគយ ស្តង់ដារផលិតផល សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។

ចាប់តាំងពីឆ្នាំ២០១០ ប្រទេសស្ថាបនិកអាស៊ានទាំង៦ បានលុបបំបាត់ពន្ធគយលើពាណិជ្ជកម្មក្នុងទំនិញ ចំនួន៩៩ភាគរយក្នុងតំបន់។ ATIGA បានចូលជាធរមានកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ ដោយបានសម្រេចនូវសមិទ្ធផលសំខាន់ៗនឹងបានផ្តល់នូវសុខដុមនីយកម្ម និងតម្លាភាពជាច្រើនសម្រាប់ធុរកិច្ចក្នុងអាស៊ាន ហើយក៏បានដោះស្រាយនូវបញ្ហាស្មុគស្មាញទាក់ទងនឹងតម្រូវការសម្រាប់ការធ្វើធុរកិច្ចនៅក្នុងទីផ្សារដែលបានធ្វើសមាហរណកម្មមួយនេះផងដែរ។ បន្ថែមពីនេះ មេដឹកនាំអាស៊ាន បានអនុម័តលើផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន កាលពីខែតុលា ឆ្នាំ២០១០ ដើម្បីពន្លឿនដំណើរការតភ្ជាប់អាស៊ានទាំងក្នុង និងក្រៅតំបន់ រួមមានយន្តការដៃគូសន្ទនាក្រៅតំបន់ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីតាមវិស័យ កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ។ល។

រហូតមកដល់បច្ចុប្បន្ន យើងឃើញថាអាស៊ាន មានការអភិវឌ្ឍជាវិជ្ជមានប្រកបដោយបុរេសកម្មរវាងសមាជិកអាស៊ាន ជាមួយបណ្តាប្រទេសអាស៊ីបូព៌ា បន្ថែមពីនេះ អាស៊ានបានបង្ហាញជាសក្ខីភាពក្នុងការទទួលស្គាល់លើកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងការចូលជាធរមានបន្ថែមទៀតលើកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ញូវហ្សឺឡែន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មលើទំនិញអាស៊ាន-ឥណ្ឌា។ ក្រៅពីនេះសមាជិក

អាស៊ានទាំង១០ប្រទេស ក៏បានដើរតួនាទីដ៏សំខាន់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាក្នុងតំបន់ ដែលជា "អ្នកតភ្ជាប់" ក្នុងបណ្តាប្រទេសនានាដែលមានវិសាលភាពធំជាងគេក្នុងអាស៊ី។

ពិតណាស់ ភាគរយដ៏ធំនៃពាណិជ្ជកម្មក្នុងតំបន់អាស៊ានមានសិទ្ធិទទួលបានពន្ធគយទាប ឬសូន្យ បើទោះបីមានឧបសគ្គបន្តិចបន្តួច ពាក់ព័ន្ធនឹងរបាំងមិនមែនពន្ធគយក៏ដោយ ក៏ពាណិជ្ជកម្មក្នុងតំបន់អាស៊ានបានប្រើប្រាស់អត្រាអនុគ្រោះ AFTA កាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ ឧបសគ្គចាំបាច់មួយចំនួន ជាឧទាហរណ៍ គោលដៅដើម្បីការពារបរិស្ថាន ឬសុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ ហើយករណីចាំបាច់ផ្សេងទៀត គឺធ្វើពាណិជ្ជកម្មបង្ខូចថ្លៃ ឬទុច្ចរិត និងការរឹតបន្តឹងការប្រកួតប្រជែងជាដើម។

សរុបសេចក្តីមក អាស៊ានពិតជាបានដើរតួនាទីដ៏សំខាន់ក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ហើយក៏ជាមជ្ឈមណ្ឌលដ៏សម្បូរបែបទាំងការវិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ អប់រំ វប្បធម៌ បច្ចេកវិទ្យា ទំនាក់ទំនង និងព័ត៌មាន កម្លាំងពលកម្មជំនាញ និងធ្វើជាកន្លែងប្រសព្វនៃការផ្គត់ផ្គង់ និងតម្រូវការជាច្រើនផ្សេងទៀតផងដែរ។ បច្ចុប្បន្ន ប្រជាជនអាស៊ានសរុបមានជាង ៦៣៤.៥លាននាក់ ដែលស្មើនឹងទំហំដ៏ធំទី៣ បន្ទាប់ពីចិន និងឥណ្ឌា និងមានផ.ស.ស ក្នុងមនុស្សម្នាក់សរុបមានកំណើន ៧០ភាគរយ ស្មើនឹង ៤,០៣៤ ដុល្លារសហរដ្ឋអាមេរិក ដោយក្នុងនោះប្រទេសសឹង្ហបុរីមានផលបូកផ.ស.ស ច្រើនជាងគេទី១ ក្នុងចំណោមប្រទេសជាសមាជិកទាំង១០ ដែលបង្ហាញពិភពលោកពីទំហំទីផ្សារតម្រូវការដ៏ធំសម្រាប់វិស័យវិនិយោគ ពីគ្រប់មជ្ឈដ្ឋានជុំវិញពិភពលោក។

ដើម្បីសម្រេចបាននូវសក្តានុពលពីសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺអាស្រ័យនៅលើការចូលរួមរបស់យើងទាំងអស់គ្នា និងការអនុវត្តប្រកបដោយស្មារតីជាមួយនឹងការដើរតួនាទីដ៏សំខាន់របស់អាស៊ានទាំងក្នុងតំបន់ និងពិភពលោក ដើម្បីឲ្យស្របទៅនឹងបរិបទនៃចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ៕

Ministry of Commerce

ASEAN-JAPAN Centre

# ដំណើរវិវឌ្ឍន៍នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន

# THE CURRENT DEVELOPMENT OF ASEAN ECONOMIC COMMUNITY




Prepared by: Department of Trade Policy

General Directorate of Trade Promotion of Ministry of Commerce

Vol. 2

**CONTENT**

Description Page

Forward
1. Acronyms ..... 69
2. Overview of ASEAN ..... 71
   2-1. Introduction ..... 71
   2-2. ASEAN Foundations and Identity ..... 72
   2-3. ASEAN Pillars ..... 73
   2-4. Vision, Mission and Aims ..... 73
   2-5. ASEAN Emblem and Flag ..... 75
3. Road Towards the AEC ..... 77
4. ASEAN Economic Integration ..... 81
5. ASEAN Free Trade Area “AFTA” ..... 85
   5-1. Trade Facilitation Initiatives ..... 87
   5-2. Rule-Based Trade Arrangement ..... 89
   5-3. Ultimate Target of AFTA: Elimination of all Import Duties ..... 90
   5-4. External Economic Linkages ..... 90
6. Progress of ASEAN Economic Community ..... 92
7. ASEAN and Dialogue Partners ..... 101
8. Cambodia-Japan Relation and Cooperation ..... 114
   8-1. Diplomatic Relation ..... 114
   8-2. Bilateral Economic and Trade Relation ..... 115
